# ការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្ស៖

# ទ្រឹស្តីនិងការអនុវត្តសម្រាប់តុលាការកម្ពុជា

**Application of Human Rights Treaties: Theory and Practice for Cambodian Courts**

## មាតិកា


ខ្លឹមសារចម្បង ........................................ ១

១. សេចក្តីផ្តើម ........................................ ២

២. សន្ធិសញ្ញា ស្តីពីសិទ្ធិមនុស្ស ........................................ ២

២.១. អនុសញ្ញាស្តីពី ការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ........................................ ៤

២.២. កាតព្វកិច្ចការពារ និងគោរពសិទ្ធិមនុស្ស ........................................ ៦

២.៣. ការបំពានសិទ្ធិមនុស្ស និង ដំណោះស្រាយ ........................................ ៨

២.៤. កាតព្វកិច្ច និងការអនុវត្តសន្ធិសញ្ញាក្នុងស្រុក ........................................ ១១

២.៤.១. ទ្រឹស្តីពាក់ព័ន្ធ នឹងការអនុវត្ត ........................................ ១១

២.៤.១.១. ឌូអាលីស (Dualist) and ម៉ូនីស (Monist) ........................................ ១១

២.៤.២. ការអនុវត្តរបស់រដ្ឋ (ប្រសិទ្ធភាពក្នុងស្រុក) ........................................ ១២

៣. ការអនុវត្តសន្ធិសញ្ញា ក្នុងស្រុកដោយផ្ទាល់ ........................................ ១២

ក. សន្ធិសញ្ញា ឬបទប្បញ្ញត្តិស្វ័យអនុវត្តខ្លួនឯង ........................................ ១២

ខ. លក្ខខណ្ឌចូលជាធរមាន និងការអនុវត្ត ........................................ ១៣

គ. ខ្លឹមសារនៃបទប្បញ្ញត្តិសន្ធិសញ្ញា និងច្បាប់ក្នុងស្រុក ........................................ ១៤

ឃ. ការអនុវត្តផ្ទាល់ និងទ្រឹស្តីនៃការបែងចែកអំណាច ........................................ ១៤

ង. បទប្បញ្ញត្តិផ្តល់សិទ្ធិ និង បទប្បញ្ញត្តិជាក់លាក់ ........................................ ១៤

៤. សន្ធិសញ្ញាសិទ្ធិមនុស្ស និងកម្ពុជា ........................................ ១៦

៤.១. ការចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ........................................ ១៦

៤.២. ការអនុវត្តសន្ធិសញ្ញាក្នុងស្រុក ........................................ ១៨

៤.២.១. មូលដ្ឋានច្បាប់ ........................................ ១៨

៤.២.២. ការអនុវត្តនសន្ធិសញ្ញា ........................................ ២០

៤.២.២.១. ស្ថានភាពទូទៅនៃការអនុវត្តផ្ទាល់នៃសន្ធិសញ្ញាដោយតុលាការ ........................................ ២១

ក. បទប្បញ្ញត្តិសន្ធិសញ្ញា ដូចនឹងបទប្បញ្ញត្តិក្នុងច្បាប់ជាតិ ........................................ ២២

ខ. ករណីដែលច្បាប់ជាតិ មិនបានចែង ឬចែងខុះមិនដូចសន្ធិសញ្ញា ........................................ ២២

គ. ទំនាស់រវាងបទប្បញ្ញត្តិ ........................................ ២៤

៥. សង្ខេប....................................................................................................................................២៤
៦. ឯកសារយោង និង ឧបសម្ព័ន្ធ ...........................................................................................................២៦
៦.១. ឯកសារយោង.........................................................................................................................២៦
៦.២.ឧបសម្ព័ន្ធ ស្តីពី បទប្បញ្ញត្តិច្បាប់ ......................................................................................................២៩

# ខ្លឹមសារចម្បង

កាតព្វកិច្ចឲ្យមានការគោរពសិទ្ធិមនុស្ស ក្នុងសន្ធិសញ្ញា ដែលរដ្ឋណាមួយចូលជាភាគី ទាមទារឲ្យមានយន្តការចម្រុះជាក់ស្តែង ដូចជាតាមផ្លូវតុលាការ ដើម្បីផ្តល់សំណងមានប្រសិទ្ធភាពដល់ជនរងគ្រោះនៃអំពើបំពានសិទ្ធិមនុស្ស។ ក្នុងការសម្រេចជាក់ស្តែង តុលាការមានតួនាទីសំខាន់ និងចុងក្រោយធ្វើឲ្យសិទ្ធិលើក្រដាស ក្លាយជាការពិតអនុវត្តជាក់ស្តែង យ៉ាងហោចណាស់សិទ្ធិចម្បង ដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់នានាៗ។

បន្ទាប់ពីបានពិនិត្យមើលទ្រឹស្តី និងការអនុវត្តរបស់តុលាការបរទេស ព្រមទាំងសាលក្រម ឬសាលដីការបស់តុលាការកម្ពុជាមួយចំនួន ការស្រាវជ្រាវរកឃើញថា ការអនុវត្តជាក់ស្តែងនូវខ្លឹមសារសិទ្ធិមនុស្សដោយតុលាការកម្ពុជានៅមានកម្រិត ដោយគ្រាន់តែជាការយោងដល់មាត្រា ឬឈ្មោះសន្ធិសញ្ញា មិនក្នុងអត្ថន័យនៃការអនុវត្តផ្តល់នូវប្រសិទ្ធភាពផ្ទាល់ឡើយ។ នេះអាចបណ្តាលមកពីចំណេះដឹង ឬសមត្ថភាព ដែលតម្រូវឲ្យមានការបណ្តុះបណ្តាលទ្រឹស្តីសិទ្ធិមនុស្ស ក្នុងចំណោមចៅក្រម ឬមេធាវីឲ្យកាន់តែស៊ីជម្រៅ ជាមួយការបង្ហាញនូវបទពិសោធន៍អនុវត្តផ្ទាល់របស់តុលាការបរទេស ក្នុងការប្រើប្រាស់ទ្រឹស្តីសិទ្ធិមនុស្សក្នុងសេចក្តីសម្រេច។ ជាមួយគ្នានេះដែរ ការធ្វើអង្កេតជាទ្រង់ទ្រាយធំមួយក្នុងចំណោមចៅក្រមពាក់ព័ន្ធ ការអនុវត្តសិទ្ធិ ទំនងជាការចាំបាច់ សម្រាប់ជាមូលដ្ឋានបណ្តុះបណ្តាល ឬដាក់ចេញនូវច្បាប់ ឬសេចក្តីណែនាំពាក់ព័ន្ធនឹងការគោរព ឬអនុវត្តសិទ្ធិមនុស្សដោយតុលាការ។ ក្នុងអង្កេត ឬការស្រាវជ្រាវណាមួយនាពេលខាងមុខ បញ្ហាមួយ គួរត្រូវបានដោះស្រាយ អំពីទំនាក់ទំនងរវាងតុលាការទូទៅ និងក្រុមប្រឹក្សាធម្មនុញ្ញ ថាតើតុលាការធម្មតា អាចពិនិត្យមើលបណ្តឹងពាក់ព័ន្ធនឹងសិទ្ធិមានក្នុងច្បាប់ធម្មនុញ្ញ (constitutional rights) ឬត្រូវតែជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញតែប៉ុណ្ណោះ។

## ១. សេចក្តីផ្តើម

រដ្ឋជាភាគី បានទទួលយកនូវសន្ធិសញ្ញា មកអនុវត្តក្នុងស្រុក ដោយស្ថាប័នជំនាញនីមួយៗរបស់ខ្លួន ក្នុងនោះ ក៏មានតុលាការផងដែរ ដែលជាអង្គបកស្រាយ វិភាគថាមានការបំពានសិទ្ធិមនុស្សឬយ៉ាងណា មុននឹងសម្រេចផ្តល់នូវសំណង ដល់ការបំពានសិទ្ធិ។ ជាទ្រឹស្តី វាមានការងាយស្រួល ក៏ប៉ុន្តែការអនុវត្តជាក់ស្តែង និងផ្ទាល់ វាពិតជាមានការលំបាកស្មុគ្រស្មាញខ្លាំងណាស់ទាំងផ្នែកបច្ចេកទេស និងឆន្ទៈ ឬស្មារតីនៃអ្នកអនុវត្ត។

អត្ថបទស្រាវជ្រាវនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីជួយជាគំនិតពិចារណា សម្រាប់ការអនុវត្តផ្ទាល់នូវសន្ធិសញ្ញា ស្តីពីសិទ្ធិមនុស្សក្នុងកម្ពុជា ដោយតុលាការកម្ពុជា ដែលនឹងជាផ្នែកមួយជួយឲ្យការលើកកម្ពស់ និងគោរពសិទ្ធិមនុស្ស កាន់តែប្រសើរ។ អត្ថបទ នឹងបង្ហាញជាដំបូងនូវទ្រឹស្តី និងពិនិត្យមើលក្របខ័ណ្ឌច្បាប់កម្ពុជា តាមរយៈការឆ្លើយនូវសំណួរចម្បងមួយចំនួន ដូចជាថាៈ តើតុលាការកម្ពុជា មានសមត្ថកិច្ចពិនិត្យ មើលបណ្តឹងសិទ្ធិមនុស្ស ដែលប្តឹងមកដែរឬទេ? ហើយសំណួរពាក់ព័ន្ធដទៃទៀត នឹងត្រូវបានបំភ្លឺតាមរយៈការពិនិត្យមើលជាចម្បងក្របខ័ណ្ឌច្បាប់កម្ពុជា និងការអនុវត្តអន្តរជាតិ។ អត្ថបទនឹងពិនិត្យ ពិភាក្សា ឯកសារពាក់ព័ន្ធនឹងសិទ្ធិស្ត្រីផងដែរ ក្នុងន័យមួយចំណែក ដើម្បីបញ្ជ្រាបការលើកកម្ពស់ និង ការពារសិទ្ធិស្ត្រី។

## ២. សន្ធិសញ្ញា ស្តីពីសិទ្ធិមនុស្ស

សន្ធិសញ្ញា ត្រូវបានផ្តល់ន័យថាៈ ជាកិច្ចព្រមព្រៀងអន្តរជាតិរវាងរដ្ឋ និងរដ្ឋ ក្នុងទម្រង់ជាលាយលក្ខអក្សរ និងគ្រប់គ្រងដោយច្បាប់អន្តរជាតិ។[1] សន្ធិសញ្ញា ជាប្រភពនៃច្បាប់អន្តរជាតិ។[2] សន្ធិសញ្ញា មានច្រើនប្រភេទ ដូចជា ជាក់លាក់ ឬទូទៅ ដែលផ្តោតលើប្រធានបទទូទៅ ក្នុងទម្រង់ ទ្វេភាគី ឬពហុភាគី។[3] ដំណើរការឈានដល់សន្ធិសញ្ញាចូលជាធរមាន ចាប់ផ្តើមពីការអនុម័តបើកឲ្យរដ្ឋចុះហត្ថលេខា។[4] ការចូលជាធរមាន អាស្រ័យទៅតាមការកំណត់របស់សន្ធិសញ្ញានីមួយៗ។ ជាក់ស្តែង សន្ធិសញ្ញា

---

[1] United Nations, សន្ធិសញ្ញា វៀនណា ស្តីពីច្បាប់សន្ធិសញ្ញា (Vienna Convention on Law of Treaties: VCLT), United Nations, Treaty Series, vol. 1155, p. 331, available at: https://www. refworld.org/ docid/3ae6b3a10.html [accessed 6 September 2020]

[2] United Nations, លក្ខន្តិកៈ នៃតុលាការយុត្តិធម៌អន្តរជាតិ (Statue of International Court of Justice: ICJ), 18 April 1946, available at: https://www.refworld.org/docid/3deb4b9c0.html [accessed 3 October 2020], មាត្រា ៣៨។

[3] ធម្មនុញ្ញអង្គការសហប្រជាជាតិ ជាកិច្ចព្រមព្រៀង ឬសន្ធិសញ្ញាពហុភាគី និងទូទៅ ដោយសារធម្មនុញ្ញបានចែងអំពីបញ្ហាជាច្រើនពាក់ព័ន្ធនឹងអង្គការសហប្រជាជាតិ ដូចជា គោលបំណង ស្ថាប័នសំខាន់ៗជាដើម។

[4] ជាក់ស្តែង អនុសញ្ញាស្តីពី ការប្រឆាំងនឹងអំពើទារុណកម្ម ត្រូវបានពិភាក្សាជាយូរមកហើយ ទើបមកដល់ឆ្នាំ ១៩៨៤ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័ត បើកឲ្យចុះហត្ថលេខា តាមរយៈសេចក្តីសម្រេចលេខ ៣៩/៤៦, Ian Brownlie and Guy S. Goodwin-Gill, Borwnlie's Documents on Human Rights, 6th Ed., 2010, p. 434.

ខ្លះទាមទារ ឲ្យរដ្ឋចំនួនកំណត់ណាមួយ តម្កល់ឯកសារចូលជាភាគី ដែលក្រោយពេលនោះ សន្ធិសញ្ញានឹងចូលជាធរមាន ។ មាត្រា ៤៩(១) *កតិកាសញ្ញានេះ ចូលជាធរមានក្នុងរយៈពេល៣ខែក្រោយពីកាលបរិច្ឆេទនៃការតម្កល់លិខិតតូបករណ៍ឲ្យសច្ចាប័ន ឬលិខិតតូបករណ៍សុំចូលជាសមាជិកទី៣៥ ទៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ*។[5]

រដ្ឋដែលចូលជាភាគីក្រោយពេលសន្ធិសញ្ញាចូលជាធរមាន តាមរយៈការផ្តល់សច្ចាប័ន (ratification) ឬ ទទួលយក (accession) នឹងក្លាយជាភាគី ក្រោយរយៈពេលជាក់លាក់មួយ។ ឧទាហរណ៍ រដ្ឋ *ក* បានតម្កល់ឯកសារផ្តល់សច្ចាប័ន ឬទទួលយក ក្នុងខែ មីនា ឆ្នាំ ២០១០ ក្រោយពេលដែលសន្ធិសញ្ញាចូលជាធរមាន ក្រោយរយៈពេលបីខែ គឺក្នុងខែ មុថិនា ឆ្នាំ ២០១០ សន្ធិសញ្ញា នឹងចូលជាធរមានសម្រាប់រដ្ឋ *ក*។[6]

ក្រោយពីក្លាយជាភាគី រដ្ឋមានកាតព្វកិច្ចចងដោយសន្ធិសញ្ញា។ កាតព្វកិច្ចនោះ ក្នុងទម្រង់ជាវិធានការច្បាប់ រដ្ឋបាល សង្គម ឬតុលាការ ដូចដែលមាត្រា ២ បានចែង៖ *បើមិនទាន់មានចែងក្នុងច្បាប់ដែលមានស្រាប់ ឬក្នុងវិធានការដទៃទៀតទេ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាចាត់វិធានការចាំបាច់ ស្របតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់ខ្លួន និងស្របតាមបទបញ្ញត្តិទាំងឡាយនៃកតិកាសញ្ញានេះដោយសម្រួលដល់ការអនុម័តវិធានការច្បាប់ ឬវិធានការផ្សេងទៀត ដែលចាំបាច់ ដើម្បីធ្វើឲ្យសម្រេចបាននូវសិទ្ធិទាំងឡាយ ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ*។[7]

កាតព្វកិច្ចនេះ ចងដល់អំណាចទាំងបី មានសភា រដ្ឋាភិបាល ឬ តុលាការ។ សភាធ្វើច្បាប់ ឬកែច្បាប់ ដើម្បីឲ្យមានសង្គត់ភាពជាមួយសន្ធិសញ្ញា ឬអនុវត្តសន្ធិសញ្ញា។ តុលាការ ជាអង្គបកស្រាយសន្ធិសញ្ញា រីឯរដ្ឋាភិបាល ជាអំណាចនីតិប្រតិបត្តិ អនុវត្តតាមការសម្រេចរបស់តុលាការ ដើម្បីធានាការអនុវត្តសន្ធិសញ្ញា។ អនុសញ្ញា ស្តីពី ការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី បានចែងយ៉ាងច្បាស់ថា៖ *រដ្ឋភាគីត្រូវ..លុបចោលនូវបទប្បញ្ញត្តិព្រហ្មទណ្ឌទាំងឡាយណា ដែលបង្កើតនូវការរើសអើងប្រឆាំងនឹងស្ត្រី*។[8] ក្នុងការពិចារណារបាយការណ៍របស់កម្ពុជា គណៈកម្មាធិការ បានផ្តល់អនុសាសន៍ស្រដៀងនេះដែរថា៖ *កែសម្រួលនូវច្បាប់ជាតិដើម្បីលែងចាត់ស្ត្រីក្នុងអំពើពេស្យាចារជាបទល្មើសព្រហ្មទណ្ឌ*។[9]

---

[5] UN General Assembly, កតិកាសញ្ញា ស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ (International Covenant on Civil and Political Rights: ICCPR), 16 December 1966, United Nations, Treaty Series, vol. 999, p. 171, available at: https://www.refworld.org/docid/3ae6b3aa0.html [accessed 3 October 2020]

[6] មាត្រា ៤៩ នៃ ICCPR លេខយោងទី៥ ខាងលើ។

[7] ICCPR ក្នុងលេខយោងទី៥ខាងលើ។

[8] UN General Assembly, អនុសញ្ញា ស្តីពី ការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (The Convention on the Elimination of Discrimination against Women: CEDAW), 18 December 1979, United Nations, Treaty Series,

ការអនុវត្តកាតព្វកិច្ច មិនត្រូវមានភាពរើសអើងទេ ដោយផ្អែកលើមូលហេតុដូចជាភេទ។[10] បន្ថែមពីលើនេះ ការអនុវត្តមានកម្រិត ទៅតាមវិសាលភាពនៃការចុះខរក្សាសិទ្ធិមិនអនុវត្ត (reservation)[11] ឬប្រភេទនៃសិទ្ធិ។[12] ប្រសិនបើ វាជាសិទ្ធិដាច់ខាត វានឹងបង្កើតនូវកាតព្វកិច្ចដាច់ខាត ដែលរដ្ឋជាភាគី ត្រូវគោរព និងអនុវត្ត ដោយគ្មានការដោះសារ។ មាត្រា ៤ នៃកតិកាសញ្ញាស្តីពី សិទ្ធិប្រជាពលរដ្ឋ បានចែងអំពីគ្រោះអាសន្នសាធារណៈ ដូចជា សង្គ្រាម ដែលអនុញ្ញាតឲ្យអាជ្ញាធរ កម្រិតនូវសិទ្ធិមួយចំនួន ទោះបីជាយ៉ាងនេះក្តី សិទ្ធិខ្លះនៅតែមានសុពលភាព[13]៖ *បទបញ្ញត្តិខាងលើនេះ មិនអនុញ្ញាតឲ្យមានបដិបញ្ញត្តិនឹងមាត្រា៦ មាត្រា៧ មាត្រា៨ (កថាខណ្ឌទី១ និង២)មាត្រា១១ មាត្រា១៥ មាត្រា១៦ និងមាត្រា១៨*។[14]

## ២.១. អនុសញ្ញាស្តីពី ការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី

អនុសញ្ញានេះត្រូវបានអនុម័តក្នុងឆ្នាំ ១៩៧៩ និងចូលជាធរមានក្នុងឆ្នាំ ១៩៨១។ ស្រដៀងគ្នានឹងអនុសញ្ញា ឬកតិកាសញ្ញា ស្តីពីសិទ្ធិមនុស្សដទៃទៀត អនុសញ្ញានេះ ត្រូវបានចាត់ថាជាក់លាក់ ដោយចែងពាក់ព័ន្ធតែនឹងសិទ្ធិស្ត្រី។ អនុសញ្ញា បានចែងនូវកាតព្វកិច្ចទូទៅ ដល់រដ្ឋដើម្បីធានា និងការពារសិទ្ធិស្ត្រីរួមទាំងស្ត្រីនៅក្នុងទីជនបទផងដែរ។ រដ្ឋភាគី ត្រូវចាត់វិធានការដោយឡែកចម្រុះ ដើម្បីបំពេញកាតព្វកិច្ច ដូចជា វិធានការច្បាប់ ការពារសិទ្ធិស្ត្រី តាមរយៈតុលាការមានសមត្ថកិច្ច។[15]

---

vol. 1249, p. 13, available at: https://www.refworld.org/docid/3ae6b3970.html [accessed 3 October 2020], មាត្រា ២ (ឆ)។

[9] The Committee (CEDAW) recommends that the State party: (a) *Revise its national legislation to decriminalize women in prostitution*, Concluding observations on the sixth periodic report of Cambodia, CEDAW/C/KHM/CO/6, 12 November 2019, para. 29.

[10] ICCPR ក្នុងលេខយោងទី ៥ខាងលើ មាត្រា ២។

[11] សន្ធិសញ្ញាខ្លះ អនុញ្ញាតឲ្យមានចុះខរក្សាសិទ្ធិ។ នៅពេលរដ្ឋចុះខរក្សាសិទ្ធិពាក់ព័ន្ធនឹងមាត្រាមួយណា កាតព្វកិច្ច ដែលមានចែងក្នុងមាត្រានោះ មិនចងដល់រដ្ឋទេ។ សម្រាប់អត្ថន័យនៃខរក្សាសិទ្ធិមិនអនុវត្ត សូមមើលមាត្រា២ នៃ VCLT (លេខយោងទី១ ខាងលើ)។

[12] សិទ្ធិរួចផុតនៃអំពើទារុណកម្ម ត្រូវបានចាត់ថាជាសិទ្ធិដាច់ខាត, Article 4 របស់ ICPPR (លេខយោងទី៥ខាងលើ), *Prosecutor v. Anto Furundzija (Trial Judgement)*, IT-95-17/1-T, International Criminal Tribunal for the former Yugoslavia (ICTY), 10 December 1998, available at: https://www.refworld.org/cases,ICTY,40276a8a4.html [accessed 3 October 2020], paras. 144-154។ មាស បូរ៉ា *អំពើទារុណកម្ម៖ ករណីចាំបាច់ក្នុងការបង្ការជាជាងព្យាបាល* ក្នុងចំណេះដឹងទូទៅ ស្តីពីច្បាប់ (អត្ថបទស្រាវជ្រាវច្បាប់ និងយុត្តិសាស្ត្រ) ឆ្នាំ ២០២០, ទំ. ២៦-៣៣។

[13] មាត្រា ៤ នៃ ICCPR (លេខយោងទី៥ខាងលើ)។

[14] ដូចលេខយោងទី ១៣ ខាងលើ។

[15] មាត្រា ២ នៃ CEDAW (លេខយោងទី៨ខាងលើ)។

ចាប់ពីមាត្រា ២ ដល់ ១៦ មានចែងអំពីសិទ្ធិក្នុងគ្របវិស័យ ដូចជា នយោបាយ[16] អប់រំ[17] ការងារ[18] សុខភាព[19] សេដ្ឋកិច្ច និងសង្គម[20] ដែលរដ្ឋភាគី ត្រូវគោរព និងធានា។ ក្រៅពីនេះ អនុសញ្ញា បានចែង ធានានូវសមភាពរវាងបុរស និងស្ត្រី គ្របវិស័យ[21] លុបបំបាត់នូវការធ្វើអាជីវកម្មលើស្ត្រី[22] និង ទម្រង់វប្បធម៌[23] (cultural pattern) ដែលបង្ហាញ ឬនាំឲ្យមានការរើសអើងប្រឆាំងស្ត្រី។ កាតព្វកិច្ចលាតសន្ធឹងដល់កិច្ចការងារជំនួញរបស់ឯកជន ដោយតម្រូវឲ្យរដ្ឋចាត់គ្មានសុពលភាពកិច្ចសន្យាណា ដែលកម្រិតសមត្ថភាពផ្លូវច្បាប់របស់ស្ត្រី។[24]

អនុសញ្ញា មិនបានចែងហាមមិនឲ្យចុះខរក្សាសិទ្ធិមិនអនុវត្តទេ ក៏ប៉ុន្តែ ប្រសិនបើតាមខ្លឹមសារនៃមាត្រា ២៨ រដ្ឋអាចចុះខរក្សាសិទ្ធិនៅពេលផ្តល់សច្ចាប័ន កុំឲ្យតែខរក្សាសិទ្ធិនោះ ផ្ទុយនឹងគោលបំណងនៃអនុសញ្ញា។ ក្រៅពីបង្កើតគណៈកម្មាធិការ[25] ដើម្បីពិនិត្យមើលរបាយការណ៍របស់រដ្ឋភាគី និងចេញជាអនុសាសន៍ដល់រដ្ឋ[26] មិនមានយន្តការទទួលពិនិត្យបណ្តឹងបុគ្គល (individual communi-cation) និង យន្តការស៊ើបអង្កេតទេ (inquiry)។ យន្តការទាំងពីរ ត្រូវបានបង្កើតឡើងដោយពិធីសារបន្ថែមលើអនុសញ្ញានេះ ដែលត្រូវបានអនុម័ត ក្នុងឆ្នាំ ១៩៩៩ និងចូលជាធរមានក្នុងឆ្នាំ ២០០០។ ពិធីសារ ផ្តល់អំណាចដល់គណៈកម្មាធិការបង្កើតដោយអនុសញ្ញា ស្តីពី ការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ដើម្បីអង្កេត និងពិនិត្យដល់ដែនដីរដ្ឋ (រដ្ឋភាគីអនុញ្ញាត)[27] និងទទួលពាក្យបណ្តឹង ពីជនរងគ្រោះ អ្នកតំណាង ដែលអះអាងថា រដ្ឋភាគីបានបំពានសិទ្ធិ[28]។ គណៈកម្មាធិការ នឹងពិចារណាលើបណ្តឹង ចេញជាទស្សនៈ យល់ឃើញ (view) ក្នុងទម្រង់ជាអនុសាសន៍[29]។

---

[16] មាត្រា ៧ នៃ CEDAW (លេខយោងទី៨ខាងលើ)។

[17] មាត្រា ១០ នៃ CEDAW (លេខយោងទី៨ខាងលើ)។

[18] មាត្រា ១១ នៃ CEDAW (លេខយោងទី៨ខាងលើ)។

[19] មាត្រា ១២ នៃ CEDAW (លេខយោងទី៨ខាងលើ)។

[20] មាត្រា ១៣ នៃ CEDAW (លេខយោងទី៨ខាងលើ)។

[21] មាត្រា ១៥ នៃ CEDAW (លេខយោងទី៨ខាងលើ)។

[22] មាត្រា ៦ នៃ CEDAW (លេខយោងទី៨ខាងលើ)។

[23] មាត្រា ៥ នៃ CEDAW (លេខយោងទី៨ខាងលើ)។

[24] មាត្រា ១៥ នៃ CEDAW (លេខយោងទី៨ខាងលើ)។

[25] មាត្រា ១៧ នៃ CEDAW (លេខយោងទី៨ខាងលើ)។

[26] មាត្រា ១៨នៃ CEDAW (លេខយោងទី៨ខាងលើ)។

[27] UN General Assembly, (ពិធីសារបន្ថែម លើ CEDAW) Optional Protocol to CEDAW, 6 October 1999, United Nations, Treaty Series, vol. 2131, p. 83, available at: https://www.refworld.org/docid/3ae6b3a7c.html [accessed 3 October 2020] Article 8 of OP

[28] មាត្រា ២ នៃ OP to CEDAW (លេខយោងទី ២៧ ខាងលើ)។

[29] មាត្រា ៧ នៃ OP to CEDAW (លេខយោងទី ២៧ ខាងលើ)។

## ២.២. កាតព្វកិច្ចការពារ និងគោរពសិទ្ធិមនុស្ស

ច្បាប់ ឬវិធានពាក់ព័ន្ធនឹងសិទ្ធិមនុស្ស មិននៅញ្ញឹងថ្កល់ទេ (not static)។[30] ជាក់ស្ដែង ផ្ដើមចេញពីធម្មនុញ្ញអង្គការសហប្រជាជាតិ និង បទប្បញ្ញត្តនៃសេចក្ដីថ្លែងការណ៍ជាសកល ស្ដីពី សិទ្ធិមនុស្សឆ្នាំ ១៩៤៨ ដែលប្រើពាក្យពេចន៍ «ការលើកកម្ពស់» (promotion)[31] បង្ហាញពីកាតព្វកិច្ចអវិជ្ជមាន (negative obligation) មកដល់ពេលនេះ កាតព្វកិច្ចមានការប្រែប្រួលគួរឲ្យកត់សំគាល់។ រដ្ឋមានកាតព្វកិច្ចវិជ្ជមាន (positive obligation) ដែលទាមទារឲ្យមានភាពសកម្មពីអាជ្ញាធររដ្ឋ ក្នុងការធានាសិទ្ធិ និងផ្ដល់ដំណោះស្រាយមានប្រសិទ្ធភាព ដល់ជនរងគ្រោះនៃអំពើបំពានសិទ្ធិមនុស្ស ទោះបីដោយអាជ្ញាធររដ្ឋក្ដី។[32] ក្នុងសំណុំរឿងបាត់ខ្លួនដោយបង្ខំ តុលាការអន្តរទ្វីបអាមេរិកាំង បានអះអាងអំពីវត្តមាននៃកាតព្វកិច្ចប្រភេទនេះ៖ *ការបំពានសិទ្ធិមនុស្ស...អាចបង្កដោយបុគ្គលឯកជន ...នាំឲ្យរដ្ឋទទួលខុសត្រូវ... ដោយសារកង្វះការប្រឹងប្រែងបង្ការ...*។[33] ប្រភពនៃការបំពានសិទ្ធិ មិនត្រឹមតែជាអាជ្ញាធររដ្ឋក្នុងអត្ថន័យដើមនៃការគោរពសិទ្ធិមនុស្សទេ ការបំពានសិទ្ធិដោយជនស៊ីវិលលើជនស៊ីវិល ក៏ត្រូវបានទាមទារឲ្យរដ្ឋធានាដោះស្រាយផងដែរ ដូចជា ការកែសម្រួលច្បាប់ ដែលបង្កការងាយស្រួលឲ្យបុគ្គលបំពានសិទ្ធិបុគ្គល ឬជនរងគ្រោះមិនអាចប្ដឹងទៅតុលាការបានដោយសាររបាំងនៃច្បាប់។ ក្នុងរឿងក្ដីមួយ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានថ្លែងថា៖*..អាចមានកាតព្វកិច្ចវិជ្ជមានដើម្បីធានាសិទ្ធិជីវិតឯកជន...អាចតាមរយៈការប្រកាន់យកវិធានការធានានូវការគោរពរវាងទំនាក់ទំនងបុគ្គល និងបុគ្គល*។[34] រដ្ឋទទួលខុសត្រូវសងសំណងដល់ជនរងគ្រោះ (ជនល្មើស) ដែលទទួលរងទារុណកម្មដោយប៉ូលីសក្នុងអំឡុងការងាររបស់ខ្លួន ដោយមូលហេតុថា ខកខានមិនបានបណ្ដុះបណ្ដាលប៉ូលីសស្ដីពីវិធីសាស្ត្រធ្វើការងារសមស្របរបស់ប៉ូលីស (proper and acceptable methods of policing)។[35]

កាតព្វកិច្ចឲ្យអនុវត្តតាមខ្លឹមសារសន្ធិសញ្ញា ចងដល់គ្រប់ស្ថាប័នអំណាចទាំងបីរបស់រដ្ឋ[36]។ ជាក់ស្ដែង តុលាការរដ្ឋមួយនៃប្រទេសឥណ្ឌា បានអះអាងអំពីកាតព្វកិច្ចរបស់តុលាការក្នុងខ្លឹមសារ

[30] *Soering v. The United Kingdom*, 1/1989/161/217, Council of Europe: European Court of Human Rights, 7 July 1989, available at: https://www.refworld.org/cases,ECHR,3ae6b6fec.html [accessed 6 October 2020] កថាខណ្ឌទី១០២។

[31] United Nations, *Charter of the United Nations*, 24 October 1945, 1 UNTS XVI, available at: https://www.refworld.org/docid/3ae6b3930.html [accessed 6 October 2020], មាត្រាទី១ (៣)។

[32] ICCPR លេខយោងទី៩ មាត្រា ២។

[33] *Velásquez Rodríguez Case*, Inter-Am.Ct.H.R. (Ser. C) No. 4 (1988), Inter-American Court of Human Rights (IACrtHR), 29 July 1988, available at: https://www.refworld.org/cases,IACRTHR,40279a9e4.html [accessed 6 October 2020] កថាខណ្ឌទី ១៧២។

[34] *X and Y v. the Netherlands*, European Court of Human Rights, No. 8978/80, 26 March 1985, កថាខណ្ឌទី២៣។

[35] *Lamon v. Bumai*, National Court of Justice, Papua New Guinea[2010] PGNC 21, 12 March 2010, p.3.

[36] UN Human Rights Committee (HRC), *General comment no. 31 [80], The nature of the general legal obligation imposed on States Parties to the Covenant*, 26 May 2004, CCPR/C/21/Rev.1/Add.13, available at:

ថា៖...*ឯកសារអន្តរជាតិទាំងនេះ ទាមទារឲ្យឥណ្ឌា...ហើយតុលាការមានកាតព្វកិច្ចក្នុងការធានាថា ខ្លឹមសារនៃឯកសារទាំងនោះ មិនត្រូវបានបំពាន*[37]។ ប្រសិនបើមិនមានអត្ថន័យច្បាស់លាស់ក្នុងច្បាប់ទេ តុលាការមិនត្រូវផ្ទុកផ្តាក់លើចេតនាសភា ក្នុងការបដិសេធសិទ្ធិឬសេរីភាពមូលដ្ឋានទេ។[38]

សម្រាប់កាតព្វកិច្ចវិជ្ជមាននេះផងដែរ រដ្ឋក៏នឹងត្រូវទទួលខុសត្រូវ ចំពោះទង្វើរបស់អាជ្ញាធររបស់ខ្លួននៅក្រៅប្រទេស ដែលបំពានសិទ្ធិអ្នកដទៃនៅក្រៅដែនដីរបស់ខ្លួន។ មាត្រា ២ ដែលប្រើពាក្យ *រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី__និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន នូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ* ត្រូវបានបកស្រាយ ដោយជំនួស ពាក្យ «និង» ដោយពាក្យ «ឬ»។[39] បន្ថែមពីលើនេះ រដ្ឋក៏នឹងអាចរកឃើញថា បានបំពានសិទ្ធិនៃបុគ្គល កើតមានក្រៅដែនដីរបស់ខ្លួន ដោយសារតែទង្វើបណ្តេញចេញ ឬធ្វើបត្យាប័នបុគ្គលនោះទៅទីនោះ។[40] យោបល់ទូទៅនៃគណៈកម្មាធិការសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ បានចែងសរុប ស្តីពីកាតព្វកិច្ច ដែលសូមដកស្រង់នូវខ្លឹមសារថា៖ *..មាត្រា ២ ទាមទាររដ្ឋភាគីធានាសិទ្ធិដល់បុគ្គល ...ដោយមិនត្រូវធ្វើបត្យាប័ន...ទៅប្រទេស....ដែលមានហានិភ័យមិនអាចជុសជុលបាន ដូចបានចែងក្នុងមាត្រា ៦ និង ៧ នៃកតិកាសញ្ញា...*។[41]

---

https://www.refworld.org/docid/478b26ae2.html [accessed 6 October 2020] កថាខណ្ឌទី ៤ (General Comment No.31)។

[37] *បទល្មើសរុកកួនខាងផ្លូវភេទ (sexual harassment) មានភ្ជាប់ទៅនឹងសិទ្ធិចម្បង នឹងភាពស្មើគ្នានៃយេនឌ័រ និងសិទ្ធិរស់រានមានជីវិត និងសេរីភាព ដែលសិទ្ធិទាំងពីរនេះ ជាសិទ្ធិចម្បងធានាដោយរដ្ឋធម្មនុញ្ញរបស់ឥណ្ឌា។ ទាំង CEDAW និង ICESCR ទាមទារ ថាជំហានសំខាន់ត្រូវប្រកាន់យក ក្នុងការបង្ការការរើសអើងប្រឆាំងនឹងស្ត្រី។ មាត្រា ៧ នៃរដ្ឋធម្មនុញ្ញឥណ្ឌា ទទួលស្គាល់នូវសិទ្ធិស្ត្រី ក្នុងការលក្ខខណ្ឌការងារសមស្រប។ ឯកសារអន្តរជាតិទាំងនេះ បានតម្រូវឲ្យឥណ្ឌាដាក់បញ្ចូលនូវធាតុយេនឌ័រក្នុងច្បាប់ ហើយតុលាការមានកាតព្វកិច្ច ក្នុងការធានាថាខ្លឹមសារនៃឯកសារអន្តរជាតិទាំងនោះមិនត្រូវបានបំពាន*, *Apparel Export Promotion Council v. Chopra*, Supreme Court [1999] INSC 7, 20 January 1999, p.2.

[38] *Namdi v. Attorney General*, Supreme Court of Samoa [2011]WSSC 91, 3 September 2011, p. 2 printed in Pacific Human Rights Law Digest (Vol 4), p.5, 2013.

[39] General Comment No. 31 of Human Rights Committee លេខយោងទី៣៦ ខាងលើ។

[40] មាត្រា ៣ នៃអនុសញ្ញា ស្តីពី ការប្រឆាំងទារុណកម្មចែងថា៖ *មិនមានរដ្ឋណាមួយ ត្រូវបណ្តេញ បញ្ជូន ឬ បត្យាប័ន បុគ្គលណាមួយ ទៅកាន់រដ្ឋដទៃ ដែលមានមូលដ្ឋានរឹងមាំសម្រាប់ឲ្យជឿថា គាត់នឹងជួបនូវគ្រោះនៃអំពើទារុណកម្ម*, UN General Assembly, *Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment*, 10 December 1984, United Nations, Treaty Series, vol. 1465, p. 85, available at: https://www.refworld.org/docid/3ae6b3a94.html [accessed 6 October 2020]។ UN Human Rights Committee (HRC), General comment no. 31, លេខយោងទី៣៦ ខាងលើ,កថាខណ្ឌទី១០ និងទី ១២។

[41] General comment no. 31,លេខយោងទី៣៦ ខាងលើ,កថាខណ្ឌទី ៤ និងទី ១២។

សន្ធិសញ្ញា ស្ដីពី ច្បាប់សន្ធិសញ្ញា ចែងតម្រូវឲ្យរដ្ឋគោរពកាតព្វកិច្ច ដោយសុទ្ធចិត្ត៖ *គ្រប់សន្ធិសញ្ញា ដែលចូលជាធរមាន ចងកាតព្វកិច្ចលើរដ្ឋភាគី និងត្រូវបានអនុវត្តដោយសុទ្ធចិត្ត*[42] និងមិនអាចលើកយកចន្លោះខ្វះខាតនៃច្បាប់មកដោះសារ ចំពោះការខកខានក្នុងការបំពេញតាមកាតព្វកិច្ចក្នុងសន្ធិសញ្ញា ដែលរដ្ឋចូលជាភាគីដោយស្ម័គ្រចិត្តនោះទេ៖ *ភាគីណាមួយមិនអាចលើកយកបទប្បញ្ញត្តិនៃច្បាប់ជាតិរបស់ខ្លួនមកធ្វើជាយុត្តិកម្ម សម្រាប់ដោះសារការខកខានមិនបានអនុវត្តសន្ធិសញ្ញា*..។[43]

## ២.៣. ការបំពានសិទ្ធិមនុស្ស និង ដំណោះស្រាយ

សិទ្ធិមនុស្សមានច្រើនប្រភេទ។ ការបំពានសិទ្ធិ អាចកើតមានគ្រប់ពេល ទាំងពេលមានសន្តិភាព និង គ្រោះអាសន្នសាធារណៈ ដូចជាសង្គ្រាម។ ការបំពានសិទ្ធិ អាចកើតមានដោយសារអំពើរបស់ជនស៊ីវិល ឬ អាជ្ញាធរនៃអង្គតុលាការ សភា ឬ អំណាចនីតិប្រតិបត្តិ ក្នុងករណីតូច ឬទ្រង់ទ្រាយធំ។ ការធ្វើទារុណកម្ម ដោយឆ្មាំពន្ធនាគារ ក្នុងមួយករណី ជាករណីតូចមួយ។ ការធ្វើទារុណកម្មក្នុងមន្ទីរសន្តិសុខ ស២១ មានលក្ខណៈជាប្រព័ន្ធ ខ្សែសង្វាក់តាមគោលនយោបាយថ្នាក់លើ ដើម្បីយកចម្លើយពីខ្មាំង និងបង្ក្រាបខ្មាំង។ ជនរងគ្រោះ មានច្រើនមកពីគ្រប់ស្រទាប់ក្នុងសង្គម និងទូទាំងប្រទេស។[44] នេះជាការបំពានសិទ្ធិរួចផុតទារុណកម្មមួយដ៏ធ្ងន់ធ្ងរ។ ការបំពានប្រភេទនេះ អាចត្រូវបានចាត់ទុកជាបទល្មើស ប្រឆាំងនឹងមនុស្សជាតិ ដែលនាំឲ្យបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ។[45] ឌុច ដែលជាមេគុក ស២១ ត្រូវបានចោទ និងឲ្យទទួលខុសត្រូវក្នុងករណីនេះ។[46] ក្នុងករណីខ្លះ បទប្បញ្ញត្តិច្បាប់ខ្លួនឯងបំពានសិទ្ធិដោយសារ តែខ្លឹមសារមានអត្ថន័យផ្ទុយនឹង បទប្បញ្ញត្តិនៃសន្ធិសញ្ញា។ ដូចគ្នានេះដែរ ករណីខ្លះ ការបំពានសិទ្ធិមិនទាន់បង្កចេញជាផលវិបាកទេ។

កន្លែងនេះ អ្នកនិពន្ធសូមបញ្ជាក់បន្តិចពីអ្វីទៅជាការបំពានសិទ្ធិមនុស្ស ដើម្បីកាត់បន្ថយ នូវការយល់ច្រឡំ។ ឧទាហរណ៍ បុគ្គលម្នាក់ ត្រូវបានបុគ្គលម្នាក់ប្លន់យកម៉ូតូ និងធ្វើឲ្យគាត់របួស។ ជនរងគ្រោះ បានធ្វើពាក្យបណ្ដឹង និងជូនទៅតុលាការ ដើម្បីទាមទារយកសំណង និងម៉ូតូរបស់ខ្លួនមកវិញ។ ពាក្យបណ្ដឹងនេះ នាំឲ្យមានបណ្ដឹងអាជ្ញា ធ្វើឡើងដោយអាជ្ញាធរ ដើម្បីឲ្យជនល្មើសទទួល

---

[42] មាត្រា ២៦ នៃ VCLT លេខយោងទី១ខាងលើ។

[43] មាត្រា ២៧ នៃ VCLT លេខយោងទី១ខាងលើ។

[44] អវតក, សាលក្រមសំណុំរឿង ០០១, ២៦ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌទី២៣។

[45] មាត្រា ៩ នៃច្បាប់ ស្ដីពីការបង្កើតឲ្យមាន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ ២០០៤។ មាត្រា ៧ នៃ លក្ខន្តិកៈ ស្ដីពី តុលាការព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ ១៩៩៨, UN General Assembly, *Rome Statute of the International Criminal Court (last amended 2010)*, 17 July 1998, ISBN No. 92-9227-227-6, available at: https://www.refworld.org/docid/3ae6b3a84.html [accessed 7 October 2020]

[46] អវតក, សាលក្រមសំណុំរឿង ០០១, លេខយោងទី ៤៣ខាងលើ, កថាខណ្ឌទី១១១។

ខុសត្រូវតាមច្បាប់ ហើយជាលទ្ធផល ផ្តល់សំណងដល់ជនរងគ្រោះ។ អាជ្ញាធរទទួលបានពាក្យបណ្តឹង ស្វែងរក និងបានចាប់ខ្លួនជនល្មើសដាក់ពន្ធនាគារ។ ទោះបីជាយ៉ាងនេះក្តី ជនល្មើសត្រូវបានឃុំលើសរយៈពេលកំណត់ដោយច្បាប់ ហើយសវនាការបានធ្វើឡើង ៣ឆ្នាំ ក្រោយពេលបទល្មើសបានកើតមានឡើង។ ឧទាហរណ៍ទី ២ នារីម្នាក់ ត្រូវបានបណ្តេញចេញពីការងារ ដោយសារនាងមានផ្ទៃពោះ ដែលនេះអាចបំពានច្បាប់ការងារ និងច្បាប់ធម្មនុញ្ញ ដែលបានចែងហាមឃាត់។ នាងបានប្តឹងទៅតុលាការ ក៏ប៉ុន្តែតុលាការមិនបានចាត់ការអ្វីទាល់តែសោះ។

ក្នុងករណីទាំងពីរខាងលើ ជាដំបូង វាជាការបំពានច្បាប់ព្រហ្មទណ្ឌ ឬ ច្បាប់ការងារ។ ប្រសិនបើក្រោយពីទទួលពាក្យបណ្តឹង អាជ្ញាធរបានចាត់វិធានការស៊ើបអង្កេត ស្វែងរកជនល្មើស វិនិច្ឆ័យសេចក្តី ផ្តល់សំណង ហើយជនរងគ្រោះបានសំណង *នោះមិនមានការបំពានសិទ្ធិទេ។* ផ្ទុយទៅ ប្រសិនបើមិនបានចាត់ការ ឬការស៊ើបអង្កេតយឺតយ៉ាវ ដោយគ្មានហេតុផល នោះវាហួសពីការបំពានច្បាប់ ហើយក្លាយជាការបំពានសិទ្ធិ។ ក្នុងករណីនេះ តើសិទ្ធិអ្វី ដែលត្រូវបានបំពាន? ការមិនចាត់វិធានការ ហើយដែលជនរងគ្រោះ មិនទទួលបានសំណង អាចបំពានមាត្រា ២ នៃកតិកាសញ្ញា ស្តីពី សិទ្ធិប្រជាពលរដ្ឋដែលមានខ្លឹមសារ៖*ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឲ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះបានប្រព្រឹត្តិដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ*។[47] ក្នុងករណីនេះ មិនគ្រាន់តែសិទ្ធិរបស់ជនរងគ្រោះត្រូវបានបំពានទេ សិទ្ធិរបស់ជនល្មើស ក៏ត្រូវបានបំពានផងដែរ។ នោះជាសិទ្ធិសុវត្ថិភាពរបស់បុគ្គល ក្នុងអត្ថន័យថា ការឃុំខ្លួន ត្រូវចាំបាច់ និងមានមូលដ្ឋាន ព្រមទាំងការឃុំខ្លួនតាមកំណត់ច្បាប់ ដូចដែលមាត្រាចែង៖*ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់កាលណា ...ជាការចាំបាច់...*។[48] ទីនេះ គេគួរកត់សំគាល់ថា ជនល្មើសក៏អាចជាជនរងគ្រោះនៃអំពីបំពានសិទ្ធិមនុស្សផងដែរ ហើយច្បាប់សិទ្ធិមនុស្ស ក៏ដូចជាច្បាប់ជាតិ ចែងធានាផ្តល់ការពារសិទ្ធិ និងផ្លូវច្បាប់ស្មើគ្នាដល់ជនគ្រប់រូប។[49]

តើអ្វីទៅជាដំណោះស្រាយសម្រាប់ជនរងគ្រោះ? ដំណោះស្រាយ មានប្រភេទខុសគ្នាទៅតាមប្រទេសនីមួយៗ និងតាមកម្រិតនៃការបំពានសិទ្ធិ។ ក្នុងករណី ដែលបទប្បញ្ញត្តិច្បាប់ មានខ្លឹមសារផ្ទុយសន្ធិសញ្ញា ដែលអាចប៉ះសិទ្ធិមនុស្ស ហើយមិនទាន់បង្កនូវផលវិបាកប៉ះពាល់ជាក់ស្តែង តុលាការអាចចេញនូវសាលក្រម ប្រកាសថាច្បាប់ អាចបំពានសិទ្ធិ (declaratory judgement)។[50] សាលក្រម ឬសេចក្តីសម្រេចនេះ មិនផ្តល់សំណងទេ។ ក៏ប៉ុន្តែ វាធ្វើឲ្យជនដែលអាចរងគ្រោះ ដោយសារការអនុវត្តច្បាប់នាពេលខាងមុខ បានសប្បាយចិត្ត។ ស្រដៀងគ្នានេះដែរ តុលាការប្រទេសអង់គ្លេស អាចចេញ

---

[47] ICCPR លេខយោងទី៥ខាងលើ។

[48] មាត្រា នៃ ICCPR លេខយោងទី៥ ខាងលើ។ មាត្រា ២០៥ នៃ ក្រមព្រហ្មទណ្ឌនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។

[49] មាត្រា ១៤ នៃ ICCPR លេខយោងទី៥ ខាងលើ។

[50] Ken Oliphant (ed.), the Liability of Public Authorities in Comparative Perspective, 2016, pp. 305 and 543.

ធ្វើសេចក្ដីប្រកាសថាច្បាប់មិនស្រប (incompatibility declaration) នឹងសន្ធិសញ្ញា សិទ្ធិមនុស្ស អឺរ៉ុប។ នេះជួយដល់សភាដើម្បីពិចារណា ក្នុងការកែសម្រួលច្បាប់ ដែលផ្ទុយនឹងសន្ធិសញ្ញា។[51] តុលាការជាតិ ខ្លះផ្ដល់សំណងជាក់ស្ដែងចំពោះការបំពានសិទ្ធិ ដូចជា សិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដូចជាករណី ឃុំខ្លួនខុសច្បាប់ ឬការធ្វើទារុណកម្ម ដោយគិតគូរជាទឹកប្រាក់ជាក់ស្ដែង៖ *ផ្ដល់ សំណង ចំនួន ១០០,០០ ០PGK សម្រាប់ការបំពានសិទ្ធិធម្មនុញ្ញ និងសំណងជាឧទាហរណ៍ចំនួន ២៥, ០០០PGK*។[52]

ការបំពានសិទ្ធិជាបុគ្គល (ជនល្មើស) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) ក្រោយពីពិចារណា រកឃើញថា មានការឃុំខ្លួនខុសច្បាប់ បានប្រកាសថា ប្រសិនបើជនល្មើស ត្រូវបានរកឃើញថាមានទោស គាត់នឹងទទួលបានការកាត់បន្ថយទោស ឬគ្មានទោស គាត់នឹងទទួលបានសំណង៖ *ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធភាព អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ ដែលអង្គជំនុំជម្រះ នឹងត្រូវយកមកសម្រេច នៅដំណាក់កាលសម្រេចអំពីទោសចំពោះរយៈពេល ដែលគាត់ជាប់ឃុំឃាំងដោយខុសច្បាប់នៅតុលាការយោធាពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៩៩ និងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០០៧*។[53] ឯកសារសិទ្ធិមនុស្សបានចែងអំពី ការជួសជុលចំពោះការបំពានសិទ្ធិមនុស្ស (reparation) ដែលមានជាសំណង (compensation) ការបំពេញចិត្ត (sastific ation) ការធ្វើឲ្យមានស្ថានភាពដូចដើម (restitution)។[54] បន្ថែមពីលើនេះ នៅមានវិធានការ ឬសកម្មភាពដទៃទៀត ដែលច្បាប់តម្រូវដើម្បីឆ្លើយតបនឹងការបំពានសិទ្ធិមនុស្ស ដូចជា វិធានការរដ្ឋបាល

---

[51] Merris Amos, *Damages for Violations of Human Rights Law* in Ewa Baginska, *ed*., Damages for Violations of Human Rights: A Comparative Study of Domestic Legal Systems, 2016, p. 373.

[52] *Lamon v. Bumail*, Namdi v. Attorney General; *Namba v. Naru*, National Court of Justice, Papua New Guinea [2011] PGNC 124, 23, September 2011, p.2។ មួយដុល្លារសហរដ្ឋអាមេរិក ស្មើ ៣.*៥០១២៥* PGK។ សម្រាប់ព័ត៌មានផ្សេងទៀត សូមមើល មាស បូរ៉ា *តួនាទីរបស់តុលាការក្នុងការការពារសិទ្ធិចម្បង* ក្នុងចំណេះដឹងទូទៅស្ដីពីច្បាប់ (អត្ថបទស្រាវជ្រាវច្បាប់ និងយុត្តិសាស្ត្រ) ឆ្នាំ ២០២០, ទំ. ៧៩-៩១។

[53] ខ្លឹមសារដកស្រង់សេចក្ដីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ E39/5 ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៩ (សំណុំរឿង ០០១) ទំ.២៦ និង២៧។ ក្នុងសាលក្រម ០០១ អង្គជំនុំជម្រះសាលាដំបូង នៃអវតក បានសម្រេចកាត់បន្ថយទោសចំនួន ៥ ឆ្នាំ ដើម្បីជាសំណងដល់ការឃុំខ្លួន ឌុច ដោយបំពានដោយតុលាការយោធា, អវតក, សាលក្រមសំណុំរឿង ០០១, លេខ យោងទី៤៣ខាងលើ, កថាខណ្ឌទី ៦៨០។ ។

[54] សំណង សំដៅលើការផ្ដល់ជាលុយកាក់ ដូចជាសម្រាប់ព្យាបាលជំងឺ។ ការបំពេញចិត្ត ជាការធ្វើឲ្យជនរងគ្រោះ សប្បាយចិត្ត ដូចជា ការសារភាពទទួលស្គាល់កំហុសរបស់ជនល្មើស។ ការធ្វើឲ្យមានស្ថានភាពដូចដើម ដូចជាការដោះលែងឲ្យមានសេរីភាព ឬ ប្រគល់វត្ថុដែលបាត់ជូនជនរងគ្រោះវិញ។ Ewa Baginska, *Damages for Violations of Human Rights: A Comparative Analysis* in Ewa Baginska, *ed*., Damages for Violations of Human Rights: A Comparative Study of Domestic Legal Systems, 2016, pp. 459-460. UN General Assembly, *Basic Principles and Guidelines on the Right to a Remedy and Reparation for Victims of Gross Violations of International Human Rights Law and Serious Violations of International Humanitarian Law : resolution / adopted by the General Assembly*, 21 March 2006, A/RES/60/147, available at: https://www.refworld.org/docid/4721cb942.html [accessed 7 October 2020] កថាខណ្ឌទី១៥ ដល់ ២៣។

(ការដកតំណែងដល់មន្ត្រី ដោយសារតំណែងនោះនាំឲ្យមានការបំពានសិទ្ធិ) ការស្តាកាយសម្បទា (ដូចជាការព្យាបាលផ្លូវចិត្តជនរងគ្រោះនៃអំពើទារុណកម្ម)[55] ឬការកែច្បាប់ជាដើម។ ជាសរុប ដំណោះស្រាយ វាអាស្រ័យទៅតាមប្រភេទនៃការបំពានសិទ្ធិ ដែលការបំពានខ្លះទាមទារ នូវវិធានការ ឬសកម្មភាពច្រើន រួមគ្នាឆ្លើយតប ដើម្បីដោះស្រាយ និងបង្កាកុំឲ្យមានការបំពានជាថ្មី។ ក្នុងខ្លឹមសារនេះដើម្បីកុំឲ្យមានភាពស្មុគ្រស្មាញ និងមានការចោទប្រកាន់ថា រដ្ឋបានបំពានសិទ្ធិនាំឲ្យមានការទទួលខុសត្រូវច្រើន និងស្មុគ្រស្មាញ។ *ការបង្កាពិតជាប្រសើរជាងការព្យាបាល*។ សកម្មភាពមួយផ្នែកគឺការផ្សព្វផ្សាយសិទ្ធិមនុស្ស ដល់អាជ្ញាធរ និងប្រជាពលរដ្ឋឲ្យបានជ្រួតជ្រាប។

## ២.៤. ភាតពូកិច្ច និងការអនុវត្តសន្ធិសញ្ញា ក្នុងស្រុក

### ២.៤.១. ទ្រឹស្តីពាក់ព័ន្ធ និងការអនុវត្ត

### ២.៤.១.១. ឌូអាលីស (Dualist) and ម៉ូនីស (Monist)

ជាដំបូង យើងគួរលើកយកទ្រឹស្តីពីរ ដែលពាក់ព័ន្ធមកបង្ហាញ។ ឌូអាលីស សំដៅថា មានប្រព័ន្ធច្បាប់ជាតិ និងអន្តរជាតិ ដែលមានប្រភពរៀងៗខ្លួន។[56] ជាទូទៅ ច្បាប់ជាតិខ្ពស់ជាងច្បាប់អន្តរជាតិ[57] ហើយច្បាប់ខាងក្រោយនេះ មិនអាចមានប្រសិទ្ធភាពក្នុងស្រុកទេ (direct effect) ប្រសិនបើមិនមានច្បាប់បផ្លែងច្បាប់អន្តរជាតិទៅជាច្បាប់ក្នុងស្រុកទេ (part of national legal system)។[58] ផ្ទុយទៅវិញ ម៉ូនីស អះអាងថា មានប្រភពច្បាប់តែមួយទេ ហើយច្បាប់ជាតិ និងអន្តរជាតិ ទាញចេញពីប្រភពនេះ។[59] ច្បាប់អន្តរជាតិ មានប្រសិទ្ធភាពក្នុងស្រុក ក្រោយពីរដ្ឋបានទទួលយក ហើយក្នុងករណីមានទំនាស់ ច្បាប់អន្តរជាតិត្រូវខ្ពស់ជាង។[60] ទោះបីជាយ៉ាងនេះក្តី វាជាទ្រឹស្តី ហើយដែលការអនុវត្តហួសពីនេះ ដោយសារ ភាពស្មុគ្រស្មាញ និងប្រែប្រួល។

---

[55] មាត្រា ១៤ នៃ Torture Convention លេខយោងទី ៣៩ ខាងលើ។

[56] David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, 2009, p. 6 (David Sloss, the Role of Domestic Courts).

[57] Last in time rule applied by the Courts of the United States, example, Jacques deLisle, *Damages Remedies for Infringements of Human Rights under U.S. Law* in Ewa Baginska, *ed*., Damages for Violations of Human Rights, លេខយោងទី៥០ខាងលើ p. 409.

[58] David Sloss, the Role of Domestic Courts លេខយោងទី ៥៥ ខាងលើ ទំ. ៧។

[59] David Sloss, the Role of Domestic Courts, លេខយោងទី ៥៥ ខាងលើ ទំ. ៨១។

[60] Shin Hae Bong, *Japan*, p. 375; Nora Chronowski, *Hungary*, p. 265; Hans-Peter Folz, *Germany*, p. 245; Emmanuel Decaux, *France*, p. 216 in Dinah Shelton, International Law and Domestic Legal Systems: Incorporations, transformation, and persuasion, 2011, (Dinah Shelton, International Law)។ Katrin Lange, Awareness and application of CEDAW in the judicial systems of Germany and France (Working Paper No. 15), 2017, p. 14.

### ២.៤. ២. ការអនុវត្តរបស់រដ្ឋ (ប្រសិទ្ធភាពក្នុងស្រុក)

នៅពេលសន្ធិសញ្ញា ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋ (ក្លាយជាភាគី) សម្រាប់ប្រទេសមួយចំនួន ដែលគ្មានការចូលរួមរបស់សភា ក្នុងដំណើរការផ្តល់សច្ចាប័នលើសន្ធិសញ្ញា សន្ធិសញ្ញាចងជាកាតព្វកិច្ចនៅកម្រិតអន្តរជាតិ និងមិនទាន់មានប្រសិទ្ធភាពក្នុងស្រុកទេ។[61] ប្រទេសដែលសភាចូលរួម តាមរយៈការអនុម័តយល់ព្រម ឲ្យរដ្ឋាភិបាលផ្តល់សច្ចាប័នលើសន្ធិសញ្ញា មានប្រសិទ្ធភាពក្នុងស្រុកហើយ។ ក្នុងន័យថា សន្ធិសញ្ញា គឺជាផ្នែកនៃប្រព័ន្ធច្បាប់ជាតិ។[62] សភារបស់ប្រទេសប្រភេទទីមួយ ត្រូវធ្វើច្បាប់ធ្វើឲ្យសន្ធិសញ្ញាក្លាយជាច្បាប់ក្នុងស្រុកជាមុនសិន។[63]

## ៣. ការអនុវត្តសន្ធិសញ្ញា ក្នុងស្រុកដោយផ្ទាល់

### ក. សន្ធិសញ្ញា ឬបទប្បញ្ញត្តិស្វ័យអនុវត្តខ្លួនឯង

ការអនុវត្តផ្ទាល់ក្នុងស្រុក (direct application) គឺជាការអនុញ្ញាតឲ្យ ភាគីលើកយកមាត្រានៃសន្ធិសញ្ញា មកមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ហើយតុលាការ ឬអាជ្ញាធរយកមកពិភាក្សាថាតើមានការបំពានមាត្រាដែរឬទេ? បើមានដំណោះស្រាយ (remedy) អាចត្រូវសម្រេច។ វានឹងមិនមែនជាបញ្ហាទេ ប្រសិនបើ សន្ធិសញ្ញា ឬបទប្បញ្ញត្តិ អាចស្វ័យអនុវត្តបាន (self-executing treaty/pro vision)។ គេអាចនិយាយថា បើវាជាសន្ធិសញ្ញា ឬបទប្បញ្ញត្តិប្រភេទនេះ វាអាចអនុវត្តដោយផ្ទាល់ក្នុងស្រុកបានហើយ។

ទ្រឹស្តីសន្ធិសញ្ញា ឬបទប្បញ្ញត្តិស្វ័យអនុវត្តបាន មានប្រភពមកពីសហរដ្ឋអាមេរិក[64] តែទោះបីជាយ៉ាងនេះក្តី ប្រទេសស៊ីវិលឡខ្លះ ក៏ប្រកាន់យកផងដែរពាក់ព័ន្ធការអនុវត្តសន្ធិសញ្ញាក្នុងស្រុក។[65] សម្រាប់សន្ធិសញ្ញាស្វ័យអនុវត្តឬមិន គឺផ្អែកលើកត្តាមួយចំនួន ក្នុងនោះមានចេតនារបស់ភាគីរៀបចំសន្ធិសញ្ញា ឬ សន្ធិសញ្ញាចែង។[66] ក៏ប៉ុន្តែ វាពិតជារឿងកម្រ ដែលមានចែងក្នុងសន្ធិសញ្ញា ឬ អ្នក

---

[61] Jerry Z. Li and Sanzhuan Guo, *China*, p. 168 in Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។

[62] Sean D. Murphy, Does International Law Obligate States to Open Their National Courts to Persons for the Invocation of Treaty Norms That Protect or Benefit Persons? in David Sloss, the Role of Domestic Courts, លេខយោងទី ៥៥ ខាងលើ ទំ. ៨១។

[63] Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ ទំ.១០។ Sir Ian Sinclair, *United Kingdom*, p. 733 in Duncan B. Hollis, Merritt R. Blakeslee and L. Benjamin Ederington ed., National Treaty Law and Practice: Dedicated to the Memory of Monroe Leigh, Vol.I, 2005។

[64] Carlos Manuel Vazquez, The Four Doctrines of Self-Executing Treaties, 89 American Journal of International Law 695-723, p. 700 (1995).

[65] Shin Hae Bong, *Japan*, p. 368, in Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។

[66] Carlos Manuel Vazquez, The Four Doctrines លេខយោងទី ៦៣ ខាងលើ ទំ. ៧០០។

រៀបចំ មានចេតនាដូចនេះ ពីព្រោះការអនុវត្តសន្ធិសញ្ញាក្នុងស្រុក វាជារឿងមួយដ៏ស្មុគ្រស្មាញ។ សម្រាប់បទប្បញ្ញត្តិវិញ វាមានភាពងាយស្រួល ដោយពិចារណាលើខ្លឹមសារនៃបទប្បញ្ញត្តិជាក់ស្តែង ឬអាជ្ញាធររដ្ឋ ជាអ្នកកំណត់។ ជាក់ស្តែង ច្បាប់ស្តីពីសន្ធិសញ្ញាវៀតណាម តម្រូវឲ្យអាជ្ញាធរសាមី ដែលផ្តួចផ្តើមការចរចារចុះសន្ធិសញ្ញា ជាអ្នកអះអាងស្នើប្រាប់សភាថា មាត្រាណាខ្លះគួរស្វ័យអនុវត្តបាន។[67] បទប្បញ្ញត្តិស្វ័យអនុវត្តបាន មានន័យជាសាមញ្ញគឺបទប្បញ្ញត្តិ ដែលតុលាការអាច ពិភា ក្សា សំអាង ដោយមិនចាំបាច់មានច្បាប់តម្រូវពីសភា។ មាត្រា ៤ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ទាមទារច្បាប់របស់សភា ដើម្បីចាត់អំពើទារុណកម្ម ជាបទល្មើសជាមុនសិន មុនតុលាការអាចអនុវត្តបាន។[68] ច្បាប់នេះ ជាច្បាប់សម្រាប់អនុវត្ត (implementing act) បទប្បញ្ញត្តិមិនស្វ័យអនុវត្ត (non-executing provision)។ ច្បាប់ប្រភេទនេះ ខុសពីច្បាប់របស់សភានៃប្រទេសកំមុនឡ ធ្វើឲ្យសន្ធិសញ្ញាជាផ្នែកមួយនៃច្បាប់ក្នុងស្រុក (transformation act/statute)។[69]

## ខ. លក្ខខណ្ឌចូលជាធរមាន និងការអនុវត្ត

ជាការអនុវត្ត ភាពស្មុគ្រស្មាញបានកើតមានហួសពីស្វ័យភាពអនុវត្តនៃសន្ធិសញ្ញា ឬបទប្បញ្ញត្តិនៃសន្ធិសញ្ញា។ ក្រុមប្រាកដនិយម នឹងទាមទារឲ្យសន្ធិសញ្ញា ត្រូវចូលជាធរមានជាមុនសិនមុននឹងអាចអនុវត្តក្នុងស្រុកបាន។ បន្ថែមពីលើនេះ ប្រទេសខ្លះ ដូចជាបារាំង គោលការណ៍នីត្យានុកូល និងភាពប្រាកដប្រជានៃច្បាប់អនុវត្តសម្រាប់ច្បាប់ជាតិ បានអនុវត្តសម្រាប់សន្ធិសញ្ញាផងដែរ គឺតម្រូវឲ្យមានការបោះផ្សាយសន្ធិសញ្ញាជាភាសាជាតិក្នុងទស្សនាវដ្តីរដ្ឋ (official gazette) ជាមុនសិន មុននឹងត្រូវបានលើកមកសំអាងមុខតុលាការ (អនុវត្តក្នុងស្រុក)។[70] អ្នកនិពន្ធ យល់ថាវាជាការត្រឹមត្រូវ ក៏ប៉ុន្តែ វាមិនគួរយឺតយូរពេកទេ ពីព្រោះ វានឹងជាឧបសគ្គមួយ មិនអាចឲ្យសន្ធិសញ្ញាអាចអនុវត្តក្នុងស្រុកបាន។ អ្វីដែលធ្ងន់ធ្ងរជាងនោះ គឺករណីដែលសន្ធិសញ្ញា បានតម្រូវឲ្យផ្តល់ប្រសិទ្ធភាពក្នុងស្រុកភ្លាមៗ។[71] បញ្ហានេះដូចគ្នាដែរ ចំពោះតម្រូវការនៃច្បាប់ធ្វើសន្ធិសញ្ញា ឲ្យក្លាយជាផ្នែកមួយនៃច្បាប់ជាតិ។ ខណៈដែលសភាយឺតយូរក្នុងការធ្វើច្បាប់ប្រភេទនេះ ការអនុវត្តបាន នៅតែមិនអាចធ្វើបាន ខណៈដែលរដ្ឋបានចងជាកាតព្វកិច្ចរួចហើយលើឆាកអន្តរជាតិ តាមរយៈការផ្តល់សច្ចាប័នដោយរដ្ឋាភិបាល ទោះបីមិនមានការចូលរួមរបស់សភាក្តី។

[67] Law on Treaties, No. 108/2016/QH13, 2016, Article 15, https://vanbanphapluat.co/law-108-2016-qh13-on-treaties.

[68] មាត្រា ៤នៃ Torture Convention លេខយោងទី៣៩ ខាងលើ។

[69] Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ ទំ.១០។

[70] Shin Bae Bong, *Japan*, p.365; Francisco Ferreira de Almeida, *Portugal*, p. 504 in Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។

[71] ICCPR លេខយោងទី៥ ខាងលើ មាត្រា ២។

### គ. ខ្លឹមសារនៃបទប្បញ្ញត្តិសន្ធិសញ្ញា និងច្បាប់ក្នុងស្រុក

នៅពេលសន្ធិសញ្ញាបានចូលជាធរមានរួចហើយ សភាបានធ្វើច្បាប់ ចែងនូវខ្លឹមសារនៃបទប្បញ្ញត្តិដូចគ្នា (ចម្លង) នឹង បទប្បញ្ញត្តិនៃសន្ធិសញ្ញា ឬខ្លឹមសារខុសគ្នាបន្តិចបន្តួច ឬក្នុងករណីខ្លះ មិនមានចែងទាល់តែសោះក្នុងច្បាប់ជាតិ។ ឧទាហរណ៍ ច្បាប់ជាតិចែងអំពីមូលដ្ឋាននៃការរើសអើង ក៏ប៉ុន្តែមិនបានបញ្ចូលមូលដ្ឋានភេទឡើយ។ ស្រដៀងគ្នានេះដែរ ច្បាប់ជាតិ មិនបានចែងនូវសិទ្ធិអាចប្តឹងឧទ្ធរណ៍ទេ។ ក្នុងករណីដូចគ្នា តុលាការនឹងពិនិត្យមើលតែច្បាប់ជាតិ ក្នុងមូលដ្ឋានថា ប្រសិនបើមានច្បាប់ជាតិហើយ ប្រើប្រាស់បទប្បញ្ញត្តិនៃច្បាប់ជាតិនោះទៅ។[72] ករណីមិនមានចែង ឬក៏ចែងខ្វះខាត មិនដូចគ្នា តុលាការនៃប្រទេសខ្លះ នឹងយោងតាមខ្លឹមសារនៃសន្ធិសញ្ញាអន្តរជាតិ ដើម្បីផ្តល់នូវអាទិភាពនៃសិទ្ធិនោះ។[73] ជាក់ស្តែង តុលាការអះអាងថា ទោះបីច្បាប់រដ្ឋធម្មនុញ្ញ មិនបានចែង អំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ក៏ប៉ុន្តែសន្ធិសញ្ញា ដែលរដ្ឋជាភាគីមានចែងអំពីសិទ្ធិ តុលាការប្រកាសទទួលយកសិទ្ធិ។[74]

### ឃ. ការអនុវត្តផ្ទាល់ និងទ្រឹស្តីនៃការបែងចែកអំណាច

ពាក់ព័ន្ធនឹងកង្វះច្បាប់ជាតិនេះផងដែរ តុលាការប្រទេសខ្លះ ប្រើប្រាស់ការបកស្រាយឲ្យស្រប និងផ្តល់ប្រសិទ្ធភាព (principle of conformity[75]) ដល់ខ្លឹមសារនៃសន្ធិសញ្ញា។ ទោះបីជាយ៉ាងនេះក្តី ក្នុងរឿងព្រហ្មទណ្ឌ តុលាការបកស្រាយតឹងរឹង មិនផ្អែកតាមខ្លឹមសារនៃសន្ធិសញ្ញា នាំឲ្យមានការអនុវត្តក្នុងស្រុកផ្ទាល់នៃសន្ធិសញ្ញាពាក់ព័ន្ធនឹងព្រហ្មទណ្ឌឡើយ។[76] នេះទំនងជាពាក់ព័ន្ធនឹងសិទ្ធិសេរីភាពបុគ្គល ហើយការចាត់ថាមានបទល្មើស ទាមទារនូវច្បាប់របស់សភា។ ការបកស្រាយទូលាយពេកដោយតុលាការ អាចប៉ះដល់គោលការណ៍នៃការបែងចែកអំណាច។

### ង. បទប្បញ្ញត្តិផ្តល់សិទ្ធិ និង បទប្បញ្ញត្តិជាក់លាក់

កាលណាបើនិយាយអំពីការអនុវត្តផ្ទាល់ក្នុងស្រុក គឺសំដៅដល់ការប្រើប្រាស់ ឬបកស្រាយបទប្បញ្ញត្តិនៃសន្ធិសញ្ញាដោយតុលាការ។ ដើម្បីបានដល់ការពិនិត្យដោយអង្គនេះ ជនរងគ្រោះត្រូវមានសិទ្ធិប្តឹងទៅតុលាការ (right to access to court)។ សិទ្ធិនេះ ជួនកាលមិនត្រូវបានចែងច្បាស់ទេ ឬជួនកាលត្រូវបានចែងច្បាស់នៅក្នុងសន្ធិសញ្ញាចង្អុលឲ្យប្តឹងប្រសិនបើមានការបំពានបទប្បញ្ញត្តិជាក់លាក់

---

[72] Jerry Z. Li and Sanzbuan Gua, *China*, p. 126 in Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។

[73] High Court of Tanzania, *Ephrahim v. Pastory & Kazilege*, 22 Febraury 1990, p.2.

[74] Draft Report on Case-Law Regarding the Supremacy of International Human Rights Treaties, European Commission for Democracy Through Law, Study no. 304/2004, 2004, p.5.

[75] Talia Einborn, *Israel*, p.311; Stepen Beaulac and John H. Currie, *Canada*, p. 149, Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។

[76] Stephen C. Neff, *United Kingdom*, p. 626 in Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។

ឬសិទ្ធិសញ្ញាទាំងមូល (right of action)។ នៅពេលប្តឹង តុលាការនឹងទទួល ហើយសម្រេចថា ទទួលយកទៅពិចារណាឬមិន វាអាស្រ័យទៅលើថា បទប្បញ្ញត្តិបើកសិទ្ធិឲ្យប្តឹងដែរឬទេ? ពាក់ព័ន្ធនឹងបញ្ហានេះ គេគួរតែពិចារណារវាង ច្បាប់សារធាតុ (law of substance) និងនីតិវិធី (procedural law)។ ភាគីជនរងគ្រោះ បានប្តឹងទៅតុលាការរដ្ឋប្បវេណី បង្ខំឲ្យរដ្ឋមួយ ដែលភ្នាក់ងារបានបំពានសិទ្ធិ។ តុលាការ នឹងបដិសេធបណ្តឹងដោយសារ តាមវិធានទំនៀមទម្លាប់អន្តរជាតិ រដ្ឋមានអភ័យឯកសិទ្ធិរួចផុតពីការប្តឹងរដ្ឋប្បវេណីដើម្បីទារសំណង។[77] នេះពាក់ព័ន្ធនឹងបញ្ហានីតិវិធី។

ក្នុងករណី មិនមែនមានច្បាប់ផ្តល់នូវសិទ្ធិប្តឹង តុលាការនឹងពិនិត្យមើលខ្លឹមសារនៃបទប្បញ្ញត្តិថាតើមានភាពជាក់លាក់ អាចវិនិច្ឆ័យបាន (justiciability) បង្កានូវការបំពានជ្រុលរបស់តុលាការ លើអំណាចសភាក្នុងការធ្វើច្បាប់។[78] បទប្បញ្ញត្តិផ្តើមដោយពាក្យ «*..គ្មាននរណាមួយ*»....ចែងផ្តល់សិទ្ធិ អនុញ្ញាតឲ្យបុគ្គលអាចប្តឹងបាន[79]...រីឯមាត្រា យោងដល់ពាក្យ «*ការអនុវត្តជាបណ្តើរៗប្រសើរឡើង*» (progressive realization) មិនអាចអនុវត្តបានទេ ដោយសារ វាមានខ្លឹមសារទូទៅ ចែងនូវការប្តេជ្ញាចិត្តរបស់រដ្ឋ។[80] ជាចុងក្រោយ ផ្អែកតាមវិស័យដែលទាមទារនូវការបកស្រាយតឹងតែង សន្ធិសញ្ញាស្តីពីព្រហ្មទណ្ឌ តុលាការប្រទេសខ្លះ មិនបកស្រាយឲ្យមានអនុវត្តផ្ទាល់ ដោយគ្មានអន្តរាគមន៍របស់សភា ធ្វើច្បាប់ចាត់អំពីក្នុងសន្ធិសញ្ញា ជាបទល្មើសជាតិ ដែលតុលាការអាចសម្រេចបានទេ។[81]

ជាចុងក្រោយក្នុងករណីដែលមិនមានច្បាប់ចែង ទង្វើបំពានសិទ្ធិ អាចត្រូវបានចាត់ថា ជាទង្វើអនីត្យានុកូលភាព ដែលនាំឲ្យអាជ្ញាធរទទួលខុសត្រូវ។ ក្នុងករណីខ្លះ ជាលទ្ធផល សេចក្តីសម្រេចរដ្ឋបាល ដូចជា...ត្រូវបានមោឃៈភាព ដោយសារបំពានសិទ្ធិមនុស្ស។[82]

---

[77] Giuseppe Cataldi, *Italy*, p. 344 in Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។

[78] Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ ទំ.៥។

[79] Shin Hae Bong, *Japan*, p.369 in Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។

[80] Shin Hae Bong, *Japan*, 370 in Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។

[81] Stephen C. Neff, *United Kingdom*, p. 626 in Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។

[82] Shin Hae Bong, *Japan*, p. 370 in Dinah Shelton, International Law លេខយោងទី៥៩ ខាងលើ។ Jane Wright, Tort Law and Human Rights, 2001។Donald R. Rothwell, *Australia*, p.137 in David Sloss, the Role of Domestic Courts, លេខយោងទី ៥៥ ខាងលើ។

## ៤. សន្ធិសញ្ញា សិទ្ធិមនុស្ស និងកម្ពុជា

### ៤.១. ការចុះហត្ថលេខា ផ្ដល់សច្ចាប័ន និងចូលជាធរមាន

កម្ពុជា មិនទាន់មានច្បាប់ ឬអនុក្រឹត្យណាចែងលម្អិត អំពីការចុះហត្ថលេខា រហូតដល់ការអនុវត្តនៃសន្ធិសញ្ញាក្នុងស្រុកទេ។ ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានចែងរាយប៉ាយក្នុងមាត្រាមួយចំនួនអំពីសមាសភាគនៃច្បាប់អន្តរជាតិ ដូចជាការចុះហត្ថលេខា។ ក្នុងឆ្នាំ ២០១៨ ក្នុងច្បាប់ស្ដីពីការរៀបចំគណៈរដ្ឋមន្ត្រី មានមាត្រាមួយបានចែងបន្ថែមៈ *នាយករដ្ឋមន្ត្រីដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ការពារជាតិ សន្តិសុខជាតិ និងវិស័យផ្សេងទៀតដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល។ នាយករដ្ឋមន្ត្រី អាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនណាម្នាក់ ជាអ្នកចរចា និងចុះហត្ថលេខា។ បែបបទ និងនីតិវិធីនៃការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំងនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។*[83]

ព្រះមហាក្សត្រ ជាបុគ្គលមានសិទ្ធិចុះហត្ថលេខា លើអនុសញ្ញា ឬសន្ធិសញ្ញា។[84] ទោះបីជាយ៉ាងនេះក្ដី ជាទម្លាប់រហូតដល់ឆ្នាំ ២០១៨ មុនមានច្បាប់ចែង ប្រធានស្ថាប័ន (ជាមួយលិខិតផ្ទេរសិទ្ធិពីប្រមុខរាជរដ្ឋាភិបាល) ឬ រដ្ឋមន្ត្រីការបរទេស បានចុះហត្ថលេខាលើសន្ធិសញ្ញាឬកិច្ចព្រមព្រៀងជាហូរហែរ។[85]បន្ទាប់ពីការចុះហត្ថលេខា ក្រសួងមួយចំនួន ក្រោយពីពិភាក្សា ឬសុំយោបល់ នឹងធ្វើការជាមួយក្រសួងការបរទេស ដើម្បីបំពេញនីតិវិធីឲ្យកម្ពុជាជាភាគី នៃកិច្ចព្រមព្រៀង។ ផ្សេងពីនេះ ប្រសិនបើភាគីម្ខាង ឬមានមាត្រានិយាយច្បាស់ឲ្យកម្ពុជាផ្ដល់សច្ចាប័ន ក្រសួងសាមី (ចុះហត្ថលេខា) នឹងបន្តនីតិវិធី ដើម្បីសុំសច្ចាប័ន។ ត្រង់ចំណុចនេះ មានការយល់ឃើញខ្វែងគ្នា។ ក្រុមម្ខាងដោយផ្ដោតលើពាក្យប្រើក្នុងច្បាប់រដ្ឋធម្មនុញ្ញ អះអាងថា ឲ្យតែអនុសញ្ញា និងសន្ធិសញ្ញា ត្រូវតែមានការផ្ដល់សច្ចាប័ន[86] ដែលជាទូទៅផ្ដល់ការយល់ព្រមពីសភា។ ពាក្យ «អនុស្សរណៈ» ឬ«ពិធីសារ» មិនត្រូវបានប្រើទេក្នុងច្បាប់រដ្ឋធម្មនុញ្ញ ក៏ប៉ុន្តែ មានពិធីសារជាច្រើន ត្រូវបានផ្ដល់សច្ចាប័ន[87] ដោយសារមានការទាមទារដូចនេះ ដោយពិធីសារ ឬ ផ្អែកតាមការបកស្រាយ ថាច្បាប់រដ្ឋធម្មនុញ្ញមិនបានហាម។ ក្រុមម្ខាង អះអាងថា គេមិនត្រូវផ្ដោតទៅលើឈ្មោះនៃលិខិតូបករណ៍អន្តរជាតិនោះទេ។ ក៏ប៉ុន្តែ គេត្រូវពិនិត្យ មើលខ្លឹមសារ ដែលអាចចែងជាកាតព្វកិច្ចដល់រដ្ឋទាំងមូល ឬវិស័យ ដែលសភា ត្រូវអន្ត

---

[83] ច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីឆ្នាំ ២០១៨។ មកដល់ខែតុលា ឆ្នាំ ២០២០ នេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានធ្វើសេចក្ដីព្រាងអនុក្រឹត្យរួចហើយ។

[84] ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ២៦ថ្មី។

[85] ឧទាហរណ៍ អនុសញ្ញាអន្តរជាតិ ស្ដីពីការលុបបំបាត់ចោលនូវការផ្ដល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម (ចុះហត្ថលេខាដោយក្រសួងមហាផ្ទៃ)។

[86] នេះដោយយោងដល់មាត្រា ៩០ ថ្មី នៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។

[87] ឧទាហរណ៍ពិធីសារបន្ថែមលើ CEDAW។

ភាគមន៍ តាមរយៈការផ្តល់សច្ចាប័ន។ ផ្អែកលើមូលដ្ឋាននេះហើយ ទើបអនុស្សរណៈ មិនត្រូវបានទាមទារឲ្យ ផ្តល់សច្ចាប័នទេ ដោយសារ វាអាចជាកិច្ចព្រមព្រៀង បច្ចេកទេសរវាង អង្គភាពក្រោមស្ថាប័នរដ្ឋ។[88]

គេគួរកត់សំគាល់ នូវពាក្យពេចន៍ ដែលប្រើនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញបន្តិច *ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា*[89]។ តាមពិត មិនមែនព្រះមហាក្សត្រទេ ដែលផ្តល់សច្ចាប័ន ព្រះមហាក្សត្រ គ្រាន់តែឡាយព្រះហស្តលេខា លើច្បាប់ ស្តីពី ការអនុម័តយល់ព្រមដែលមានពីរ[90] ឬ បី[91] ឬ បួនមាត្រា[92] របស់សភាតែប៉ុណ្ណោះ។ នៅពេលដែលកិច្ចព្រមព្រៀងឬសន្ធិសញ្ញា ត្រូវបានចុះហត្ថលេខារួច ហើយទាមទារនូវការផ្តល់សច្ចាប័ន ក្រសួងសាមី នឹងរៀបចំសេចក្តីព្រាងសេចក្តីថ្លែងហេតុ (គោលបំណងនៃការចូលជាភាគី...) និងសេចក្តីព្រាងច្បាប់ ដែលឯកសារទាំងអស់នេះ ត្រូវបានពិនិត្យពិចារណា និងដាក់ចូលអង្គប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី។ បន្ទាប់ពី មានការអនុម័តរួចសេចក្តីព្រាងច្បាប់ រួមនឹងសេចក្តីថ្លែងហេតុ ព្រមទាំងអត្ថបទបកប្រែសន្ធិសញ្ញាជាភាសាខ្មែរ ត្រូវបានបញ្ជូនទៅសភា និងព្រឹទ្ធសភា ដើម្បីអនុម័ត។ ព្រះមហាក្សត្រ នឹងឡាយព្រះហស្តលេខាប្រកាសឲ្យប្រើច្បាប់ ដែលក្នុងមាត្រាមួយបានចែងៈ *រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ*។[93] តាមរយៈនេះ ក្រសួងការបរទេស នឹងរៀបចំនីតិវិធី ផ្ញើឯកសារទៅតម្កល់ ដើម្បីឲ្យកម្ពុជា បានក្លាយជាភាគីសន្ធិសញ្ញា ឬជាសមាជិករបស់ស្ថាប័នអន្តរជាតិ។

---

[88] ឯកសារនេះ មិនត្រូវបានសុំការអនុម័តយល់ព្រមពីសភាទេ សូមមើល https://www.nbc.org.kh/english/news_and_events/news_info.php?id=261

[89] ច្បាប់រដ្ឋធម្មនុញ្ញ មាត្រា ២៦ថ្មី។

[90] ច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីការហាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន ឆ្នាំ ១៩៩៩។

[91] ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីពីរ ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ទីក្រុងម៉ានីល ឆ្នាំ ១៩៩៨។

[92] ច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃទីភ្នាក់ងារធានាការវិនិយោគពហុភាគី ឆ្នាំ ១៩៩៩។

[93] ច្បាប់ស្តីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីការជួយគ្នាទៅវិញទៅមកក្នុងកិច្ចការរដ្ឋបាលគយ ឆ្នាំ ២០០៦។ សម្រាប់ព័ត៌មានបន្ថែម ពាក់ព័ន្ធសមាសភាគនៃច្បាប់អន្តរជាតិក្នុងប្រព័ន្ធច្បាប់កម្ពុជា សូមមើល Meas Bora, *the 1993 Cambodian Constitution and International Law: A Normative Perspective* in Hor Peng, Kong Phallack and Jorg MENZEL ed., Cambodian Constitutional Law, Konrad Adenauer Stiftung, 2016, pp. 69-87។

## ៤.២. ការអនុវត្តសន្ធិសញ្ញាក្នុងស្រុក

### ៤.២.១. មូលដ្ឋានច្បាប់

ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ កម្ពុជាបានចូលជាភាគីសន្ធិសញ្ញាមនុស្សជាច្រើន រួមទាំងអនុសញ្ញា ស្តីពី ការលុបបំបាត់នូវគ្រប់ទម្រង់ការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW)។ ក្នុងឆ្នាំ ២០១០ កម្ពុជា បានផ្តល់សច្ចាប័នដល់ពិធីសារបន្ថែមលើ CEDAW ដែលអនុញ្ញាតឲ្យស្ត្រីជាជនរងគ្រោះនៃអំពើបំពានសិទ្ធិ អាចប្តឹងទៅគណៈកម្មាធិការ CEDAW។[94] មាត្រា ២ បានចែងអំពីបញ្ហានេះ។[95] នេះជាលើទី១ ដែលព្រះរាជាណាចក្រកម្ពុជា បានព្រមទទួលស្គាល់យន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិដើម្បីពិនិត្យមើលបណ្តឹងបុគ្គលប្រឆាំង នឹងអាជ្ញាធររបស់ខ្លួន។ នេះជារឿងគួរឲ្យសាទរមួយមិនអាចប្រកែកបាន ចំពោះទង្វើរបស់កម្ពុជា ក្នុងការជួយលើកកម្ពស់ និងការពារសិទ្ធិស្ត្រី ដែលក្នុងប្រវត្តិសាស្ត្រសិទ្ធិទាំងនោះ មិនត្រូវបានលើកកម្ពស់ឲ្យស្មើជាមួយបុរសទេ។ កម្ពុជានឹងរងនូវការរិះគន់ ក្នុងករណីរកឃើញថាបានបំពានសិទ្ធិស្ត្រី ទោះបីជាយ៉ាងនេះក្តី ការទទួលយន្តការបណ្តឹង ដែលតាមរយៈនេះ នាំឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាង អាជ្ញាធរទទួលបន្ទុក និងសមាជិកនៃគណៈកម្មាធិការ កម្ពុជានឹងបានរៀនសូត្រច្រើនផ្នែកបច្ចេកទេស និងទ្រឹស្តីពាក់ព័ន្ធនឹងការការពារ ព្រមទាំងការលើកកម្ពស់សិទ្ធិស្ត្រី។

ក្រោយពីចូលជាភាគីនូវសន្ធិសញ្ញាមួយចំនួន ក្នុងឆ្នាំ១៩៩២ ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដែលសរសេរបញ្ចូល ឬយោងដល់សន្ធិសញ្ញាទាំងនោះ ត្រូវបានអនុម័ត។ មាត្រា ៣១ បានចែងឲ្យគោរពនិងទទួលស្គាល់នូវសន្ធិសញ្ញា៖ *ទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ...ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសេរីភាព និងករណីកិច្ចដូចគ្នា ..ដោយឥតប្រកាន់ពូជសាសន៍...។ ការប្រើសិទ្ធិ...មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។*[96] អ្វីគួរឲ្យកត់សំគាល់នោះ មាត្រា ៣១ បាននិយាយ និងសង្កត់ធ្ងន់លើសិទ្ធិស្ត្រី និងកុមារ។ វាមិនមែនជារឿងចៃដន្យទេ។ កម្រងឯកសារនៃកិច្ចប្រជុំរបស់សភាធម្មនុញ្ញក្នុងអង្គប្រជុំ បានបង្ហាញពីចំណាប់អារម្មណ៍ ស្តីពីសិទ្ធិស្ត្រី និងចេតនា លើកកម្ពស់សិទ្ធិស្ត្រី។[97] ខ្លឹមសារមួយចែងថា៖ *អំពើលក់ដូរមនុស្សអំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាសដែល*

[94] កម្ពុជា បានចុះហត្ថលេខាក្នុងឆ្នាំ ២០០១ និង ផ្តល់សច្ចាប័នក្នុងឆ្នាំ ២០១០, https://indicators.ohchr.org/

[95] មាត្រា ២៖ *បុគ្គលគ្រប់រូបអាចដាក់ពាក្យបណ្តឹងរបស់ខ្លួន...អះអាងថាខ្លួនជាជនរងគ្រោះពីការរំលោភដោយរដ្ឋភាគីទៅលើសិទ្ធិណាមួយដែលមានចែងក្នុងអនុសញ្ញានេះ។*

[96] ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣។

[97] អគ្គលេខាធិការដ្ឋានរដ្ឋសភា កំណត់ត្រាពិស្តារ សម័យប្រជុំពេញអង្គលើកទី២ នៃសភាធម្មនុញ្ញ ឆ្នាំ ១៩៩៣, ទំ ១១២ ដល់ ១១៩។

*ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់។ ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សម្រាកនៅពេលសម្រាលកូនដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត។ រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភដើម្បីមានមុខរបរមានលទ្ធភាពព្យាបាលជំងឺឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ*។[98]

ក្រៅពីមាត្រា ៣១ មាត្រាជាច្រើននៃច្បាប់រដ្ឋធម្មនុញ្ញដដែល បានចែងអំពីសិទ្ធិស្ត្រី ដោយផ្ទាល់ ឬប្រយោល ដោយប្រើពាក្យ «*ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិ...*»។[99] មាត្រា ចែងថា *ការងារមេផ្ទះមានតម្លៃ ស្មើគ្នានឹងកម្រៃ...បានពីការងារក្រៅផ្ទះ*[100]។ មាត្រា ៤៥ បានចែងអំពីសិទ្ធិស្ត្រី ពាក់ព័ន្ធជីវិតឯកជន៖ *ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។ ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់។ បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ។*

ច្បាប់រដ្ឋធម្មនុញ្ញជាច្បាប់កំពូល ដែលចែងអំពីសិទ្ធិ និងគោលការណ៍ចម្បង។ ការណ៍ដែលមាត្រាជាច្រើន មានចែងខ្លឹមសារពាក់ព័ន្ធនឹងកិត្តិយសនិង សិទ្ធិស្ត្រី វាមិនមែនជាការចៃដន្យនោះទេ។ នេះបង្ហាញពីការយកចិត្តទុកដាក់ និងចេតនារបស់អ្នកធ្វើច្បាប់ ក្នុងការលើកកម្ពស់សិទ្ធិ និងសេរីភាពស្ត្រី។

អនុលោមតាមការចង្អុលរបស់ ច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ជាច្រើនទៀត ត្រូវបានរៀបចំឡើង ដូចជាច្បាប់ការងារ ក្រមរដ្ឋប្បវេណី ច្បាប់បោះឆ្នោត ដែលបានចែងជាថ្មីឡើងវិញ តាមខ្លឹមសារនៃមាត្រានៃច្បាប់រដ្ឋធម្មនុញ្ញ ឬថែមខ្លឹមសារបន្ថែមលើសពីនេះ។ ជាក់ស្តែងមាត្រា ៣៦ចែង *ការរៀបចំនិងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់*។[101] ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានចែងនូវមាត្រាមួយចំនួន ចាត់ទង្វើរើសអើងជាបទល្មើស ហើយដែលអ្នកប្រព្រឹត្តអាចជាបុគ្គល ឬអាជ្ញាធរ ឬនីតិបុគ្គលឯកជន អាចទទួលខុសត្រូវព្រហ្មទណ្ឌ។ មាត្រា បានចែងយ៉ាងច្បាស់ថា៖ ...*អំពើដែលមិនព្រមផ្តល់ទ្រព្យសម្បត្តិ ឬសេវាដល់បុគ្គលណាម្នាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀលទៅ ២ ០០០ ០០០ (ពីរលាន) រៀល កាលបើការមិនព្រមនេះ ផ្អែកលើមូលហេតុណាមួយដូចតទៅ៖ ១...៦- ភេទរបស់បុគ្គល*។[102] បទល្មើសទាំងនេះ អាចប្រព្រឹត្តដោយមន្ត្រីរាជការ[103] ហើយនីតិបុគ្គលអាចទទួលខុសត្រូវផងដែរ។[104]

---

[98] ច្បាប់រដ្ឋធម្មនុញ្ញ មាត្រា ៤៦។

[99] ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ៣៤ ថ្មី មាត្រា ៣៥។

[100] ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ៣៦ ។

[101] ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣មាត្រា ៣៦។

[102] មាត្រា ២៦៥ មាត្រា ២៦៦ បទផ្តល់ទ្រព្យសម្បត្តិ ឬសេវាដោយមានលក្ខខណ្ឌមាត្រា ២៦៧ បទបដិសេធក្នុងការជួលបុគ្គលឱ្យធ្វើការមាត្រា ២៦៨ បទជួលបុគ្គលឱ្យធ្វើការដោយមានលក្ខខណ្ឌ។ មាត្រា ២៦៩ បទបណ្តេញចេញ ឬដកហូតដោយមូលហេតុនៃការរើសអើង នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

[103] មាត្រា ២៧០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

ក្រៅពីទោសចម្បង ក៏នៅមានទោសបន្ថែម ដូចជា ការដកហូតសិទ្ធិខ្លះជាប្រជាពលរដ្ឋ។[105] ទោះបីជាយ៉ាងនេះក្តី គេគួរកត់សំគាល់ថា វានឹងមិនមែនជាបទល្មើសទេ ប្រសិនបើការរើសអើងនេះ មានមូលដ្ឋានដូចជា ស្ថានភាពសុខភាព របស់បុគ្គល។[106]

ជាចុងក្រោយ ផ្នែកនេះសូមបរិយាយ នូវបទប្បញ្ញត្តិមួយចំនួនទៀត និងសេចក្តីសម្រេច មកបង្ហាញ សម្រាប់ជាមូលដ្ឋាននៃការវិភាគក្នុងផ្នែកខាងក្រោមបន្ត។ មាត្រា ៣៩ ចែងថា៖ *ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទាមសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។*[107] មាត្រានេះប្រើពាក្យ «អង្គការរដ្ឋ» ហើយ មាត្រា ១២៨ថ្មី បានអះអាងថា *អំណាចតុលាការធានារក្សាអាណាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។*[108] ក្រោយពីមានច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញ បានចេញសេចក្តីសម្រេចដ៏ល្បីមួយពាក់ព័ន្ធនឹងសន្ធិសញ្ញាក្នុងប្រព័ន្ធច្បាប់កម្ពុជា៖ *ជាគោលការណ៍ក្នុងការ ជំនុំជម្រះក្តីចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស តែមួយនេះទេ ដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់។ ពាក្យថាច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិរួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិងច្បាប់អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ*។[109]

### ៤.២.២. ការអនុវត្តសន្ធិសញ្ញា

ដូចដែលបានរៀបរាប់ខាងលើ មានបទប្បញ្ញត្តិជាច្រើន មានចែងពាក់ព័ន្ធនឹងសិទ្ធិស្ត្រី រួមទាំងក្នុងច្បាប់ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។ ផ្នែកនេះ នឹងបង្ហាញ អំពីការអនុវត្តផ្ទាល់នូវបទប្បញ្ញត្តិពាក់ព័ន្ធសិទ្ធិស្ត្រីដោយតុលាការ។ មានសំណួរចម្បងមួយចំនួននឹងត្រូវដោះស្រាយជាបឋម ហើយក្នុងករណីមិនមានចម្លើយសមស្របទេ ច្បាប់អន្តរជាតិ យុត្តិសាស្ត្រ ឬសេចក្តីសម្រេចរបស់តុលាការបរទេសអាចត្រូវបានយោងដើម្បីបំភ្លឺ។

តាមប្រវត្តិសាស្ត្រ កម្ពុជា ស្ថិតនៅក្រោមអាណានិគមនិយមរបស់ប្រទេសបារាំង ដែលជាប្រភពមួយ នៃស៊ីវិលឡ។ ប្រព័ន្ធច្បាប់នៃកម្ពុជា ចង់មិនចង់ រងឥទ្ធិពលនៃប្រព័ន្ធច្បាប់ប្រទេសនេះ។[110] សមាសភាគនៃប្រព័ន្ធនេះ ឃើញមាននូវវាយប៉ាយក្នុងច្បាប់សារធាតុ ឬនីតិវិធី។ ជាក់ស្តែង ក្នុងតុលាការ មានចៅក្រមស៊ើបសួរ ដែលនោះហើយជាលំនាំនៃប្រព័ន្ធស៊ីវិលឡ។ សម្រាប់ការចុះ ឬ អនុម័តលើសន្ធិសញ្ញា ឬកិច្ចព្រមព្រៀង កម្ពុជា ជាទូទៅ តម្រូវឲ្យមានការអនុម័តយល់ព្រមជាមុន ដោយសភា

---

[104] មាត្រា ២៧៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

[105] មាត្រា ២៧២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

[106] មាត្រា ២៧១ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

[107] ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។

[108] ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។

[109] សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ លេខ០៩២/០០៣/២០០៧/កបធ.ច ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧។

[110] សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំកម្ពុជា ២០១៤ ទំ.៩៣។

មុនរដ្ឋាភិបាល សុំចូលជាភាគី។ ហេតុនេះ ទើបគេអះអាងថា កម្ពុជា ប្រកាន់តាមប្រព័ន្ធម៉ូនីស ដែលប្រទេសបារាំងក៏យកលំនាំនេះដែរ។ ទោះបីមិនយោងដល់ម៉ូនីសក្តី ការណ៍ដែលសភាចូលរួមជាមុនក្នុងដំណើរការចូលជាភាគី ខុសពីប្រទេសប្រកាន់កំមុនឡូ សន្ធិសញ្ញា ឬកិច្ចព្រមព្រៀង ដែលកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ ចងកាតព្វកិច្ច លើឆាកអន្តរជាតិ និងក្នុងស្រុក។ គេអាចនិយាយម្យ៉ាងទៀតថា វាមានសុពលភាពក្នុងស្រុក។ មាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញ ជាពិសេសចែងសំដៅដល់សិទ្ធិស្ត្រី បន្ថែម អត្ថន័យលើជំហរនេះ ហើយទោះបីជាមិនមានមាត្រា ៣១ក៏ សុពលភាពនៃសន្ធិសញ្ញាក្នុងស្រុក ក៏មិនប្រែប្រួលឡើយ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ ២០០៧ ដកស្រង់ខាងលើ កាន់តែសរសេរច្បាស់អំពីសុពលភាពនេះ។[111] តាមទ្រឹស្តីរបស់ពួកម៉ូនីស សន្ធិសញ្ញា ត្រូវតែអនុវត្តផ្ទាល់បានហើយ ក៏ប៉ុន្តែ ការនិយាយវាមិនងាយស្រួលដូចការអនុវត្តទេ។

### ៤.២.២.១. ស្ថានភាពទូទៅនៃការអនុវត្តផ្ទាល់នៃសន្ធិសញ្ញាដោយតុលាការ

កម្ពុជា ជាប្រទេសស៊ីវិលឡ ហើយដែលការបោះពុម្ពសាលក្រម មិនមែនជាកាតព្វកិច្ចទេ។ អ្នកនិពន្ធបានព្យាយាម ប្រមូលសាលក្រម និងសាលដីការបស់តុលាការក្រុង សាលាឧទ្ធរណ៍ និងកំពូល ដើម្បីពិនិត្យ ព្រមទាំងពិចារណា អំពីវិសាលភាពកម្រិតណាដែលបទប្បញ្ញត្តិសិទ្ធិមនុស្សត្រូវបានលើក និង ពិចារណាដោយតុលាការ។ ក្នុងចំណោម សាលក្រម ឬសាលដីកា មានចំនួនតិចតួច ដែលបាននិយាយយោងដល់បទប្បញ្ញត្តិសន្ធិសញ្ញាអន្តរជាតិ។ លទ្ធផលដែលនឹងទទួលបាន នឹងមានកម្រិតតាមទិន្នន័យដែលមាន។

ក្នុងដំណើរការក្តី ជាពិសេសក្នុងសំណុំរឿងព្រហ្មទណ្ឌ មេធាវីបានលើកមាត្រានៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ព្រមទាំងបទប្បញ្ញត្តិសន្ធិសញ្ញា សិទ្ធិមនុស្ស ដែលកម្ពុជាជាភាគី។ ដូចជា មាត្រា ៣៨ ដែលនិយាយអំពីភស្តុតាង និងសិទ្ធិសុវត្ថិភាពបុគ្គល។ មេធាវី ជាទូទៅលើកថា៖ *មន្ទិលបានជាប្រយោជន៍ដល់ជនសង្ស័យ*។[112] តាមការពិនិត្យមើលសាលក្រម និងសាលដីកា ថាតើចៅក្រមពិនិត្យមើលកម្រិតណា ក៏ប៉ុន្តែ តាមឯកសារទាំងនោះ តុលាការគ្រាន់តែយោងដល់មាត្រានៃសន្ធិសញ្ញា ក្នុងខ្លឹមសារថា៖ ...*យោងដល់មាត្រា ១៤ (ឆ) នៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ ទទួលស្គាល់ក្នុងមាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញ*...។[113] តុលាការកំពូលក្នុងសំណុំរឿងមួយបានអះអាងអំពីការពិចារណាលើសិទ្ធិ៖ *យល់ឃើញថាជនជាប់ចោទ...ត្រូវបានឃុំខ្លួន...មានមូលហេតុស្របច្បាប់...តាមស្មារតី...មាត្រា៩ ចំណុចទី៣ វាក្យខណ្ឌ២ នៃអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ...តាមមាត្រា១២ ចំណុចទី២ នៃអនុសញ្ញាដដែល គឺកំណត់ផងដែរថា ជនជាប់ចោទត្រូវបានសន្មត់ថាជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបាន កំណត់ស្របតាមច្បាប់។...តុលាការកំពូល គប្បីពិចារណាអំពីសិទ្ធិសេរីភាពរបស់ជនជាប់*

[111] សូមមើលខ្លឹមសារដកស្រង់ក្នុងទំព័រមុន។

[112] ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។

[113] សាលដីកាតុលាការកំពូល លេខ ២៣៩ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣ (ឯកសារមាននៅជាមួយអ្នកនិពន្ធ)។

*ឃុំ*។[114] ស្រដៀងគ្នានេះដែរ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣ ឆ្នាំ ២០០៧ ក្រុមប្រឹក្សា ក៏បានយោងដល់បទប្បញ្ញត្តិដើម្បីជាមូលដ្ឋានសម្រេចចិត្តៈ *...ពិចារណាដល់ការណ៍ដែលកម្ពុជា ជាហត្ថលេខីនៃអនុសញ្ញា ស្តីពី ការបង្ការ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍...*។[115] តុលាការកំពូល បានគិតពីស្ថានភាពស្ត្រី ក្នុងសំណុំរឿងឃុំខ្លួនដោយអះអាងថាៈ*...ម្យ៉ាងទៀតជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ហើយជាស្ត្រីភេទ មេម៉ាយមានកូនច្រើនទាក់ក្នុងបន្ទុក ដែលត្រូវទទួលស្ថានសម្រាលទោសតាមមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល*។[116] ផ្អែកតាមលទ្ធផលខាងលើនេះ នៅមានសំណួរមួយចំនួន អាចត្រូវបានចោទឡើង និងត្រូវបានពិភាក្សាដូចខាងក្រោមៈ

### ក. បទប្បញ្ញត្តិសន្ធិសញ្ញា ដូចនឹងបទប្បញ្ញត្តិក្នុងច្បាប់ជាតិ

សេណារីយ៉ោនេះ មានជាកម្រណាស់ ដែលច្បាប់ជាតិ មានបទប្បញ្ញត្តិដូចបទប្បញ្ញត្តិទាំងអស់នៃសន្ធិសញ្ញា ដែលជារដ្ឋភាគីទេ។ នៅក្នុងករណីដែល ភាគីលើកបទប្បញ្ញត្តិជាតិ និងអន្តរជាតិដែលមានខ្លឹមសារដូចគ្នា តុលាការបរទេស នឹងពិចារណាតែច្បាប់ជាតិ ដែលត្រូវបានលើកឡើង។[117] នេះអាចមកពីភាពស្មុគ្រស្មាញ នៃសន្ធិសញ្ញា ឬសមត្ថភាពចៅក្រម ក្នុងការវិភាគច្បាប់អន្តរជាតិ ហើយការពិចារណាច្បាប់ជាតិ មានភាពងាយស្រួល។ ចៅក្រម ឬភាគីពាក់ព័ន្ធ មានសមត្ថភាពគ្រប់គ្រាន់។ ចៅក្រម ក៏អាចគិតថា វាពាក់ព័ន្ធនឹងអធិបតេយ្យភាព ក្នុងការពិនិត្យច្បាប់ជាតិជាមុន។ តុលាការកម្ពុជាក៏ទំនងមានទស្សនៈយ៉ាងនេះដែរ។ ទោះបីជាយ៉ាងនោះក្តី អ្នកគាំទ្រច្បាប់អន្តរជាតិ មិនសូវគាំទ្រទេ ពីព្រោះ វាបាត់នូវលទ្ធភាពនៃការពិចារណាច្បាប់អន្តរជាតិស៊ីជម្រៅ។

### ខ. ករណីដែលច្បាប់ជាតិ មិនបានចែង ឬចែងខ្វះមិនដូចសន្ធិសញ្ញា

យេណារីយ៉ោ នេះមានច្រើន ហើយដំណោះស្រាយ ក្នុងកម្រិតឬវិសាលភាពណាមួយ វាអាស្រ័យទៅលើជំហរ ឬយន្តការដោះស្រាយរបស់ប្រព័ន្ធច្បាប់ប្រទេសនីមួយៗ។ ឧទាហរណ៍ជាក់ស្តែង មាត្រា ៥ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៣ នៃច្បាប់ស្តីពី លក្ខន្តិកៈតំណាងរាស្ត្រ មានចែងមូលដ្ឋានដកសិទ្ធិលើសអ្វីដែលមានក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស។[118] មាត្រា ៣១ និងបន្តបន្ទាប់ក្នុងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ស្តីពីសិទ្ធិមនុស្ស មិនចែង ឬមានគ្រប់ដូចសិទ្ធិក្នុងសន្ធិសញ្ញាទេ។

តុលាការប្រទេសអាហ្វ្រិក អះអាងថា ទោះបីមូលដ្ឋានភេទ មិនត្រូវបានចែងជាមូលហេតុ

---

[114] សាលដីកាតុលាការកំពូលលេខ ៣០៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ទំ.១២។

[115] សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩។

[116] សាលដីកាតុលាការកំពូល លេខ ២៨ ខែ សីហា ឆ្នាំ ១៩៩៨ ( មាននៅជាមួយអ្នកនិពន្ធ)។ សម្រាប់ព័ត៌មានបន្ថែម សូមមើល Meas Bora, *the Supreme Court and Constitutional Council as Guardian of the constitution: Some Preliminary Remarks*, pp.115-131 in Hor Peng, Kong Phallack and Soth Sangbon ed., Perspectives on Cambodian Constitutional Law, NUM Research Series, 2020.

[117] David Sloss, the Role of Domestic Courts លេខយោងទី៥៥ ខាងលើ ទំ. ១៩។

[118] ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៣ នៃច្បាប់ស្តីពី លក្ខន្តិកៈតំណាងរាស្ត្រឆ្នាំ ២០១៥ ក្នុងមាត្រា ៥ ចែងមូលដ្ឋាននៃការកម្រិតសិទ្ធិ «ទំនៀមទម្លាប់ល្អ» ដែលមិនមានចែង នៅក្នុងកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ។

នៃការរើសអើង ក្នុងច្បាប់រដ្ឋធម្មនុញ្ញ តុលាការបានយោងដល់មូលដ្ឋាន ចែងក្នុងសន្ធិសញ្ញា ដែលរដ្ឋជាភាគី នឹងផ្អែកតាមនេះ រកយុត្តិធម៌ជូនស្ត្រីរងគ្រោះ ដោយសារច្បាប់ជាតិមានការរើសអើង។[119] ស្រដៀងគ្នានេះដែរ គឺសិទ្ធិដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ ដោយសារ មានចែងក្នុងសន្ធិសញ្ញា ដែលរដ្ឋជាភាគី ដូចនេះ រដ្ឋត្រូវគោរព និងធានាថាប្រជាពលរដ្ឋមាន សិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ ទោះបីមិនមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ ឬច្បាប់ដទៃទៀតក្តី។[120]

វាជាការលំបាក និង មិនអាចទៅរួចទេ ដែលសិទ្ធិទាំងអស់ ត្រូវចែងឲ្យបានគ្រប់គ្រាន់ទាំងស្រុង។ ក្នុងន័យនេះហើយ ទើបមានទ្រឹស្តីច្បាប់ចែងថា បើច្បាប់មិនហាម គឺមិនខុស និងអាចធ្វើបាន។ ដូចនេះ ប្រសិនបើមិនមានចែងសិទ្ធិនោះក្នុងច្បាប់ វាជាការសំខាន់ណាស់ ប្រសិនបើច្បាប់ធម្មនុញ្ញមិនហាមឃាត់។ កម្ពុជា បានចូលជាភាគីដោយស្ម័គ្រចិត្ត នូវសន្ធិសញ្ញាមានចែងអំពីសិទ្ធិ ហើយទទួលយកមកអនុវត្ត។ មាត្រា ៣១ ចែងអំពីការទទួលស្គាល់សិទ្ធិក្នុងសន្ធិសញ្ញា ដែលមានច្រើនជាង សិទ្ធិជាក់លាក់ក្នុងមាត្រាបន្តបន្ទាប់។ មាត្រា ៣៩ បានចែងតម្រូវឲ្យអង្គការរដ្ឋដោះស្រាយបណ្តឹង។ បណ្តឹងត្រូវដោះស្រាយដោយយន្តការផ្សេងៗ ក្នុងនោះក៏មានតុលាការផងដែរ។ តុលាការ មានសិទ្ធិពិនិត្យមើលបណ្តឹងគ្រប់វិស័យ ដូចជារដ្ឋបាល ហើយមាត្រា ១២៨ថ្មីតម្រូវឲ្យតុលាការគោរពសិទ្ធិ។ នេះគឺជាមូលដ្ឋានសម្រាប់ការពិចារណាបណ្តឹង និងការការពារសិទ្ធិក្នុងដំណើរការងារក្តីរបស់ខ្លួន។

ជាចុងក្រោយ ក្នុងវិស័យការពារសិទ្ធិស្ត្រី ការណ៍ដែលកម្ពុជា ទទួលស្គាល់យន្តការបណ្តឹងដោយស្ត្រីរងគ្រោះនៃការរើសអើង ក្រោមពិធីសារបន្ថែមលើ CEDAW ដោយប្រយោល វាអាចចង្អុលបង្ហាញថា តុលាការត្រូវពិនិត្យដោះស្រាយបណ្តឹងដោយស្ត្រីជាមុន មុននឹងជនរងគ្រោះ អាចប្តឹងទៅយន្តការ CEDAW។ នេះមានន័យថា CEDAW អាចអនុវត្តក្នុងស្រុកបាន បុគ្គលអាចលើកមាត្រាមកសំអាងបាន។ ប្រសិនបើមិនដូចនេះទេ ស្ត្រីមិនអាចមានសិទ្ធិប្តឹង និងសិទ្ធិទទួលបានដំណោះស្រាយអាចត្រូវចោទថាបំពាន។ ម្យ៉ាងទៀត ប្រសិនបើមិនមានសិទ្ធិប្តឹង ដំណោះស្រាយក្នុងស្រុក នឹងមិនចាំបាច់ប្រើ ឬដោយសារនីតិវិធីយឺតយ៉ាវ ឬ មិនមានលទ្ធភាពឈ្នះ។ និយាយម្យ៉ាងទៀត យើងអាចនិយាយបានថាជារួម CEDAW អាចត្រូវបានអនុវត្តផ្ទាល់ក្នុងស្រុក។

ជារួម ក្របខណ្ឌច្បាប់កម្ពុជា ទោះបីមិនមានច្បាប់ចែងអំពីសិទ្ធិជាក់លាក់ណាមួយ ក៏ប៉ុន្តែ ជារួម អាចនាំឲ្យតុលាការ បើកចំហរ ទទួលបណ្តឹង ពិនិត្យ និងផ្តល់ដំណោះស្រាយជូនជនរងគ្រោះ។ ទោះបីជាមានជំហរខាងលើក្តី តុលាការក៏ត្រូវពិនិត្យថា តើមាត្រាច្បាប់ចែងឲ្យប្តឹងឬទេ? (right to action) ឬថាលើកលែងសន្ធិសញ្ញា ឬ បទប្បញ្ញត្តិ អាចស្វ័យអនុវត្តបាន សិទ្ធិពាក់ព័ន្ធមានភាពច្បាស់លាស់ ដែលតុលាការអាចវិនិច្ឆ័យបាន ដោយគ្មានអន្តរាគមន៍ពីសភាក្នុងការធ្វើច្បាប់។

[119] High Court of Tanzania, *Ephrahim v. Pastory & Kazilege* លេខយោងទី៧៣ ខាងលើ។

[120] Draft Report on Case-Law Regarding the Supremacy of International Human Rights Treaties, លេខយោងទី៧១ ខាងលើ, ទំ. ៥៩។

### គ. ទំនាស់រវាងបទបញ្ញត្តិ

ការបកស្រាយចំណុចខាងលើ ចុងក្រោយនៅមានបញ្ហាមួយ ដែលតុលាការត្រូវដោះស្រាយក្នុងករណីមានទំនាស់ រវាងបទប្បញ្ញត្តិជាតិ និងសន្ធិសញ្ញាមនុស្ស។ នេះវាពាក់ព័ន្ធនឹងទីតាំងរបស់ច្បាប់អន្តរជាតិក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក ឬឋានានុក្រមនៃច្បាប់។ ក្របខ័ណ្ឌច្បាប់ បានចែងច្បាស់អំពីឋានានុក្រមនៃច្បាប់ជាតិ។ ជាក់ស្តែងមាត្រា ១៥០ថ្មី បានចែងថា *ច្បាប់រដ្ឋធម្មនុញ្ញជាច្បាប់កំពូល*។[121] បន្តបន្ទាប់មក មានច្បាប់ អនុក្រឹត្យ សារាចរណ៍ ឬ ប្រកាសក្រសួង ដែលខ្លឹមសារត្រូវគោរពតាមឋានានុក្រម។[122]

សំណួរអាចលើកឡើងថា តើសន្ធិសញ្ញា ខ្ពស់ជាង ឬទាបជាងច្បាប់រដ្ឋធម្មនុញ្ញ? តាមជំហរនិងការអនុវត្តបរទេសភាគច្រើន សន្ធិសញ្ញា ទាបជាងច្បាប់រដ្ឋធម្មនុញ្ញ។ តុលាការកម្ពុជា គួរតែប្រកាន់ជំហរដូចនេះដែរ ក៏ប៉ុន្តែ ជំហរនេះ មិនត្រូវដាច់ខាតទេ ដោយសារថា វាមិនប្រាកដថា អ្វីចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ សុទ្ធតែមានតម្លៃខ្ពស់។ នេះក៏ដូចគ្នាដែរ អ្វីចែងក្នុងសន្ធិសញ្ញា សុទ្ធតែមានតម្លៃខ្ពស់ដែលឈ្នះបទប្បញ្ញត្តិនៃច្បាប់ជាតិ។ ស្រដៀងគ្នានេះដែរ សិទ្ធិ និងសេរីភាព ចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញដែលចាត់ថាជាសិទ្ធិចម្បង មានឋានៈជាធម្មនុញ្ញ (constitutional rights) មិនប្រាកដថា ឈ្នះ ឬខ្ពស់ជាងសិទ្ធិចែងក្នុងសន្ធិសញ្ញាអន្តរជាតិទេ។ ដូចនេះ អ្វីជាចំណុចគន្លឹះ គឺការពិចារណា ករណីនីមួយៗដោយឡែកៗ ពាក់មួយនឹងសិទ្ធិ ឬតម្លៃនីមួយៗ ខ្ពស់ឬទាបជាង។

សម្រាប់ទំនាក់ទំនងរវាងច្បាប់ និង សន្ធិសញ្ញា គេត្រូវកត់សំគាល់ថា តាមខ្លឹមសារនៃសេចក្តីសម្រេច ឆ្នាំ ២០០៧ នៃក្រុមប្រឹក្សាធម្មនុញ្ញ ទាំងច្បាប់ ច្បាប់រដ្ឋធម្មនុញ្ញ និង សន្ធិសញ្ញា សុទ្ធតែជាច្បាប់។ ទោះបីជាយ៉ាងនេះក្តី បទប្បញ្ញត្តិពាក់ព័ន្ធ បង្ហាញថាច្បាប់ទាបជាងសន្ធិសញ្ញា ទោះបីខ្លឹមសារនៃពាក្យពេចន៍ដែលប្រើប្រាស់មានខ្លឹមសារមិនច្បាស់។[123] អ្វីដែលច្បាស់នោះ ដែលគួរដកស្រង់ គឺ *ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំសង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ត្រូវចាត់ទុកជាមោឃៈដាច់ខាត* ។[124]

## ៥. សង្ខេប

ក្រោយពីពិនិត្យនូវលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ការសិក្សានេះរកឃើញថា ក្របខណ្ឌច្បាប់មានភាពគ្រប់គ្រាន់ល្មម តាមការបកស្រាយ អាចផ្តល់សមត្ថកិច្ចដល់តុលាការ ដើម្បីពិចារណានូវពាក្យបណ្តឹងដោយបុគ្គល ដែលជាជនរងគ្រោះនៃអំពើបំពានសិទ្ធិមនុស្ស។ នេះជាពិសេស ពាក់ព័ន្ធនឹងការការពារសិទ្ធិស្រ្តី។ មានបទប្បបញ្ញត្តិក្នុងច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ជាច្រើនដទៃទៀត រួមទាំងការណ៍

[121] ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។

[122] ដូចលេខយោងទី១១៧។

[123] សូមពិនិត្យមើលតារាង ដកស្រង់ខ្លឹមសារច្បាប់ ដែលជាឧបសម្ព័ន្ធនៃអត្ថបទនេះ។

[124] ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ឆ្នាំ២០០១។

ដែលកម្ពុជា បានទទួលស្គាល់យន្តការបណ្ដឹងបុគ្គលតាមពិធីសារបន្ថែមលើ CEDAW ដែលជួយធានានូវប្រសិទ្ធភាពនៃការការពារសិទ្ធិស្ត្រី។ ទោះបីជាយ៉ាងនេះក្ដី ក្រោយពីការពិនិត្យលើសាលក្រម សេចក្ដីសម្រេច ឬសាលដីកា មួយចំនួនរបស់តុលាការកម្ពុជា ជាទូទៅ មិនថាពាក់ព័ន្ធនឹងសិទ្ធិស្ត្រី ឬសិទ្ធិផ្សេងៗទៀត ការអនុវត្តដោយតុលាការនៅមានកម្រិត។

ដើម្បីធានានូវប្រសិទ្ធភាពអនុវត្តសិទ្ធិ វាតម្រូវឲ្យមានភាពជាក់លាក់ពាក់ព័ន្ធនឹងមូលដ្ឋានបណ្ដឹង និងមូលដ្ឋានសម្រាប់ពិចារណា ដូចជាការផ្ដល់សំណង។ នេះទាមទារនូវភាពក្លាហានក្នុងការបកស្រាយ ផ្ដល់តម្លៃការការពារសិទ្ធិ និងផ្ដល់ប្រសិទ្ធភាពក្នុងពេលដែលមិនទាន់មានច្បាប់ចែងច្បាស់លាស់។ វាជាការចាំបាច់ក្នុងការពិនិត្យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីកែសម្រួល ឬធ្វើថ្មីដើម្បីធានាឲ្យការអនុវត្តសិទ្ធិមនុស្ស ដោយតុលាការ មិនប្រឈមបញ្ហា បច្ចេកទេស និងផ្លូវច្បាប់។

បន្ថែមពីលើនេះ ក្នុងវិស័យស្រាវជ្រាវ វាទាមទារឲ្យមានការស្រាវជ្រាវបន្ថែមពីលើអត្ថបទនេះ ដើម្បីពិនិត្យ មើលការអនុវត្តជាក់ស្ដែងរបស់តុលាការបរទេស ជាពិសេសបញ្ហាសំណងដ៏ចម្រូងចម្រាស់ តាមរយៈការធ្វើអង្កេតជាមួយចៅក្រម ដែលជាអ្នកសម្រេចសេចក្ដី អំពីការអនុវត្តសិទ្ធិមនុស្សជាក់ស្ដែងក្នុងសវនាការ ក៏ដូចជាក្នុងខ្លឹមសារនៃសាលក្រម ឬសាលដីកា។ តួនាទីរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា និងសិទ្ធិធម្មនុញ្ញភាព ក៏គួរនឹងពិនិត្យផងដែរ ដោយសារថា ក្នុងបរិបទកម្ពុជា តុលាការធម្មតានឹងមិនអាចពិនិត្យធម្មនុញ្ញភាព នៃច្បាប់ដែលផ្ទុយ នឹងសិទ្ធិចែងក្នុងធម្មនុញ្ញឡើយ។ ជាចុងក្រោយ ការបណ្ដុះបណ្ដាលស៊ីជម្រៅ អំពីទ្រឹស្ដីសិទ្ធិមនុស្ស និងបទពិសោធន៍អនុវត្តសិទ្ធិមនុស្សផ្ទាល់ដោយតុលាការបរទេសដទៃទៀត ជាការងារដំបូង និងចម្បង ដើម្បីជួយជាផ្នែកមួយ ដើម្បីធ្វើឲ្យសិទ្ធិលើក្រដាស ក្លាយជាការពិត (Make Rights into Reality)។

# ៦. ឯកសារយោង និង ឧបសម្ព័ន្ធ

## ៦.១. ឧបសម្ព័ន្ធទី១៖ ឯកសារយោង

### ១. ច្បាប់

**1.** ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។

**2.**ច្បាប់ ស្ដីពី ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ ២០០៤។

**3.**ច្បាប់ ស្ដីពី ការរៀបចំ និងប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីឆ្នាំ ២០១៨។

**4.** ច្បាប់ ស្ដីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអន្តរជាតិស្ដីពីការជួយគ្នាទៅវិញទៅមកក្នុងកិច្ចការរដ្ឋបាលគយ ឆ្នាំ ២០០៦។

**5.** ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

**6.**ច្បាប់ ស្ដីពី ការគ្រប់គ្រងឃុំសង្កាត់ឆ្នាំ ២០០១។

**7.**ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។

**8.** ច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៣ នៃច្បាប់ស្ដីពី លក្ខន្តិកៈតំណាងរាស្ត្រ ឆ្នាំ ២០១៥។

**9.** Law on Treaties, No. 108/2016/QH13, 2016, Article 15, https://vanbanphapluat.co/law-108-2016-qh13-on-treaties.

### ២. សន្ធិសញ្ញា

**1**. United Nations, សន្ធិសញ្ញា វៀនណា ស្ដីពីច្បាប់សន្ធិសញ្ញា (VCLT), United Nations, Treaty Series, vol. 1155, p. 331, available at: https://www.refworld.org/docid/3ae6b3a10.html។

**2**. United Nations, លក្ខន្តិកៈ នៃតុលាការយុត្តិធម៌អន្តរជាតិ (Statue of ICJ), 18 April 1946, available at: https://www.refworld.org/docid/3deb4b9c0.html។

**3**. UN General Assembly, កតិកាសញ្ញា ស្ដីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ (ICCPR), 16 December 1966, United Nations, Treaty Series, vol. 999, p. 171, available at: https://www.refworld.org/docid/3ae6b3aa0.html

**4**.UN General Assembly, អនុសញ្ញា ស្ដីពី ការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW), 18 December 1979, United Nations, Treaty Series, vol. 1249, p. 13, available at: https://www.refworld .org/docid/3ae6b3970.html។

**5**. UN General Assembly, (ពិធីសារបន្ថែម លើ CEDAW) OP to CEDAW, 6 October 1999, United Nations, Treaty Series, vol. 2131, p. 83, available at: https://www.refworld.org/docid/3ae6b3a7c.html

**6**.United Nations, *Charter of the United Nations*, 24 October 1945, 1 UNTS XVI, available at: https://www.refworld.org/docid/3ae6b3930.html។

**7**. UN General Assembly, *Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment*, 10 December 1984, United Nations, Treaty Series, vol. 1465, p. 85, available at: https://www.refworld.org/docid/3ae6b3a94.html

**8**.លក្ខន្តិកៈ ស្ដីពី តុលាការព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ ១៩៩៨, UN General Assembly, *Rome Statute of the International Criminal Court (last amended 2010)*, 17 July 1998, ISBN No. 92-9227-227-6, available at: https://www.refworld.org/docid/3ae6b3a84.html

## ៣. សាលក្រម ឬសាលដីកាជាតិ អន្តរជាតិ

**1**.*Prosecutor v. Anto Furundzija (Trial Judgement)*, IT-95-17/1-T, International Criminal Tribunal for the former Yugoslavia (ICTY), 10 December 1998, available at: https://www.refworld.org/cases, ICTY, 40276a8a4.html។

**2**.*Soering v. The United Kingdom*, 1/1989/161/217, Council of Europe: European Court of Human Rights, 7 July 1989, available at: https://www.refworld.org/cases,ECHR,3ae6b6fec.html [accessed 6 October 2020]

**3**.*Velásquez Rodríguez Case*, Inter-Am.Ct.H.R. (Ser. C) No. 4 (1988), Inter-American Court of Human Rights (IACrtHR), 29 July 1988, available at: https://www.refworld .org/cases ,IACR THR,40279a9e4.html

**4**. *X and Y v. the Netherlands*, European Court of Human Rights, No. 8978/80, 26 March 1985.

**5**. *Lamon v. Bumai*, National Court of Justice, Papua New Guinea[2010] PGNC 21, 12 March 2010.

**6.** *Apparel Export Promotion Council v. Chopra*, Supreme Court [1999] INSC 7, 20 January 1999.

**7.** *Namdi v. Attorney General*, Supreme Court of Samoa [2011]WSSC 91, 3 September 2011, p. 2 printed in Pacific Human Rights Law Digest (Vol 4), 2013.

**8**. *Namba v. Naru*, National Court of Justice, Papua New Guinea [2011] PGNC 124, 23 September 2011.

**9**. High Court of Tanzania, *Ephrahim v. Pastory & Kazilege*, 22 Febraury 1990.

**10.**អវតក, សាលក្រមសំណុំរឿង ០០១, ២៦ កក្កដា ឆ្នាំ ២០១០។

**11**. សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៩២/០០៣/២០០៧/កបធ.ច ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧។

**12**. សាលដីកាតុលាការកំពូល លេខ ២៣៩ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣។

**13**. សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩។

**14.**សាលដីកាតុលាការកំពូលលេខ ៣០៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៣។

**15.**សាលដីកាតុលាការកំពូល លេខ ២៨ ខែ សីហា ឆ្នាំ ១៩៩៨។

## ៤. អត្ថបទស្រាវជ្រាវ និងសៀវភៅ

**1**. Ian Brownlie and Guy S. Goodwin-Gill, Borwnlie's Documents on Human Rights, 6th Ed., 2010.

**2**. Ken Oliphant (ed.), the Liability of Public Authorities in Comparative Perspective, 2016.

**3**. Ewa Baginska, *ed*., Damages for Violations of Human Rights: A Comparative Study of Domestic Legal Systems, 2016.

**4**. David Sloss, the Role of Domestic Courts in Treaty Enforcement, A Comparative Study, 2009.

**5**. Dinah Shelton, International Law and Domestic Legal Systems: Incorporations, transformation, and persuasion, 2011.

**6**. Jane Wright, Tort Law and Human Rights, 2001.

**7.** Duncan B. Hollis, Merritt R. Blakeslee and L. Benjamin Ederington ed., National Treaty Law and Practice: Dedicated to the Memory of Monroe Leigh, Vol.I, 2005.

**8.**សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំកម្ពុជា ២០១៤។

**9**. មាស បូរ៉ា *អំពើទារុណកម្មៈ ករណីចាំបាច់ក្នុងការបង្ការជាជាងព្យាបាល* ក្នុង ចំណេះដឹងទូទៅ ស្តីពីច្បាប់ (អត្ថបទស្រាវជ្រាវច្បាប់ និងយុត្តិសាស្ត្រ) ឆ្នាំ ២០២០, ទំ. ២៦-៣៣។

**10**. Carlos Manuel Vazquez, The Four Doctrines of Self-Executing Treaties, 89 American Journal of International Law 695-723 (1995).

**11.** Meas Bora, *the Supreme Court and Constitutional Council as Guardian of the constitution: Some Preliminary Remarks*, pp.115-131 in Hor Peng, Kong Phallack and Soth Sangbon ed., Perspectives on Cambodian Constitutional Law, NUM Research Series, 2020.

**12.**មាស បូរ៉ា *តួនាទីរបស់តុលាការក្នុងការការពារសិទ្ធិចម្បង* ក្នុង ចំណេះដឹងទូទៅ ស្តីពីច្បាប់ (អត្ថបទស្រាវជ្រាវច្បាប់ និងយុត្តិសាស្ត្រ) ឆ្នាំ ២០២០, ទំ. ៧៩-៩១។

**13**. Meas Bora, *the 1993 Cambodian Constitution and International Law: A Normative Perspective* in Hor Peng, Kong Phallack and Jorg MENZEL ed., Cambodian Constitutional Law, Konrad Adenauer Stiftung, 2016, pp. 69-87។

## ៩. ផ្សេងៗ

**1**.Concluding observations on the sixth periodic report of Cambodia, CEDAW/C/KHM/CO/6, 12 November 2019, para. 29.

**2**. UN Human Rights Committee (HRC), *General comment no. 31 [80], The nature of the general legal obligation imposed on States Parties to the Covenant*, 26 May 2004, CCPR/C/21/Rev.1/Add.13, available at: https://www.refworld .org/docid/478b26ae2.html [accessed 6 October 2020]។

**3**. UN General Assembly, *Basic Principles and Guidelines on the Right to a Remedy and Reparation for Victims of Gross Violations of International Human Rights Law and Serious Violations of International Humanitarian Law : resolution / adopted by the General Assembly*, 21 March 2006, A/RES/60/147, available at: https://www.refworld.org/docid/4721cb942.html [accessed 7 October 2020]។

**4.** Katrin Lange, Awareness and application of CEDAW in the judicial systems of Germany and France (Working Paper No. 15), 2017.

**5.**អគ្គលេខាធិការដ្ឋានរដ្ឋសភា កំណត់ត្រាពិស្តារ សម័យប្រជុំពេញអង្គលើកទី២ នៃសភាធម្មនុញ្ញ ឆ្នាំ ១៩៩៣។

**6**. Draft Report on Case-Law Regarding the Supremacy of International Human Rights Treaties, European Commission for Democracy Through Law, Study no. 304/2004។

## ៦.២. ឧបសម្ព័ន្ធទី២ ស្តីពី បទប្បញ្ញត្តិច្បាប់

| ល | បទប្បញ្ញត្តិ | ប្រភព |
|---|---|---|
| | **សិទ្ធិ និងសេរីភាព** | |
| ១ | មាត្រា ៣១.-<br>ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។<br>ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គមធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។ | ច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ |
| ២ | មាត្រា ៣៦.-<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួនតាមសេចក្តីត្រូវការរបស់សង្គម។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។<br>ការងារមេផ្ទះ មានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់។<br>ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ។<br>ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់។ | ដូចខាងលើ |
| ៣ | មាត្រា ៤៥.-<br>ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។<br>ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់។<br>បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ។<br>អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាម | |

| | | |
|---|---|---|
| | គោលការណ៍ស្ម័គ្រចិត្តប្ដីមួយប្រពន្ធមួយ។ | |
| ៤ | មាត្រា ៤៦.-<br>អំពើលក់ដូរមនុស្សអំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និង អំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់។<br>ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សម្រាកនៅពេលសម្រាលកូនដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត។<br>រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភដើម្បីមានមុខរបរមានលទ្ធភាពព្យាបាលជំងឺឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ។ | |
| | **កិច្ចព្រមព្រៀង** | |
| ៥ | មាត្រា ៨.-<br>ព្រះមហាក្សត្រព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។<br>ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ។ | ដូចខាងលើ |
| ៦ | មាត្រា ២៦.-ថ្មី<br>ព្រះមហាក្សត្រ ទ្រង់ឡាយព្រះព្រះហស្ថលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា។ | ដូចខាងលើ |
| ៧ | មាត្រា ៥៥.-<br>សន្ធិសញ្ញា និង កិច្ចព្រមព្រៀងទាំងឡាយណា ដែលមិនសមស្របនឹងឯករាជ្យអធិបតេយ្យបូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវលុបចោល។ | ដូចខាងលើ |
| ៨ | មាត្រា ៩០ថ្មី(ពីរ).-<br>រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។<br>រដ្ឋសភាអនុម័តថវិកាជាតិផែនការរដ្ឋការឱ្យរដ្ឋខ្ចីប្រាក់ពីគេការ ឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើតកែប្រែ ឬលុបចោលពន្ធដារ។<br>រដ្ឋសភាឱ្យសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល។<br>រដ្ឋសភាអនុម័តច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ។<br>រដ្ឋអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។ | ដូចខាងលើ |

| | | |
|---|---|---|
| | រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម។<br>ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។<br>រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ | |
| ៩ | មាត្រា១៧ .<br>នាយករដ្ឋមន្ត្រីដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការ សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ការពារជាតិ សន្តិសុខជាតិ និងវិស័យផ្សេងទៀតដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល។<br>នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនណាម្នាក់ ជា អ្នកចរចា និងចុះហត្ថលេខា ។<br>បែបបទ និងនីតិវិធីនៃការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំងនេះត្រូវកំណត់ដោយអនុក្រឹត្យ ។ | ច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ឆ្នាំ ២០១៨ |
| ១០ | មាត្រា២៦.– ទំនាក់ទំនងជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស<br>១- យោងតាមការសម្របសម្រួលគ្នាទៅវិញទៅមក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអាចផ្លាស់ប្តូរព័ត៌មានជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសបាន លុះណាតែអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសមានកាតព្វកិច្ច រក្សាការសម្ងាត់ដូចគ្នា ដោយមិនគិតពីប្រភេទនៃអង្គភាពទាំងនោះ ។ សម្រាប់គោលបំណងនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ អាចចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអង្គភាពទាំងនោះបាន ។<br>២- នៅពេលបានទទួលសំណើសុំព័ត៌មាន ឬការបញ្ជូនព័ត៌មាន ពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុជាដៃគូនៅបរទេស អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវឆ្លើយតបតាមសំណើក្នុងដែនអំណាចនៃច្បាប់នេះ ។ | ច្បាប់ ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ២០២០ |
| ១១ | មាត្រា ១៣.<br>ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេសអន្តរជាតិក្នុងកិច្ចការត្រួតពិនិត្យទំនិញនាំចេញ និងនាំចូលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មលើកលែងតែឧស្ម័ន និងប្រេងកាត ។ | ច្បាប់ ស្តីពី គ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា ឆ្នាំ២០០០ |
| ១២ | មាត្រា ១២.<br>ការបង្វែរទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្ម លើសពីកំរិតដែលមានចែងក្នុងមាត្រា ១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត។ | ច្បាប់ ស្តីពី ការគ្រប់គ្រងធនធានទឹក |

| | | |
|---|---|---|
| | បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ។<br>ការយកខ្សាច់ ដី ថ្ម ក្រួស ប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរសមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក។ បែបបទបច្ចេកទេសជលសាស្ត្រដែលពាក់ព័ន្ធ នឹងការងារនេះនឹងមានចែងលម្អិតនៅក្នុងអនុក្រឹត្យ។<br>ការលុបទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ អាងទឹក និងអាងធម្មជាតិ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត។ បែបបទនៃការសុំនេះនឹងមានចែងនៅក្នុងអនុក្រឹត្យ។<br>ការសង់ស្ពានតូច ធំកាត់ទន្លេ ស្ទឹងកំពង់ផែ ឬសំណង់អាគារតូច ធំលើច្រាំង និងឆ្នេរ តម្រូវឱ្យមានការឯកភាពផ្នែកបច្ចេកទេសជលសាស្ត្រជាមុន ពីក្រសួងធនធានទឹក និងឧតុនិយម។<br>ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាតនិងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។ | |
| | **យន្តការ នៃការប្តឹងទាមទារ** | |
| ១៣ | មាត្រា ៣៩.-<br>ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។ | ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ |
| ១៤ | មាត្រា ១២៨ថ្មី.- )<br>អំណាចតុលាការជាអំណាចឯករាជ្យ។<br>អំណាចតុលាការធានារក្សាអាណាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។<br>អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។<br>អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។ | ដូចខាងលើ |
| ១៥ | មាត្រា ២៣.<br>ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មានសិទ្ធិទទួលបាននូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែង ដែលមានចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបាននូវសំណងសមរម្យ និងយុត្តិធម៌ ។ | ច្បាប់ ស្តីពី អស្សាមិករណ៍ឆ្នាំ២០០៩ |
| ១៦ | មាត្រា២ | កតិកាសញ្ញា ស្តីពីសិ |

| | | |
|---|---|---|
| | ១.រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន នូវសិទ្ធិដែលទទួលស្គាល់ដោយ កតិកាសញ្ញានេះ ដោយគ្មានការបែងចែកណាមួយ មានជាអាទិ៍ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ។<br>២.បើមិនទាន់មានចែងក្នុងច្បាប់ដែលមានស្រាប់ ឬក្នុងវិធានការដទៃទៀតទេ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាចាត់វិធានការចាំបាច់ ស្របតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់ខ្លួន និងស្របតាមបទប្បញ្ញត្តិទាំងឡាយនៃកតិកាសញ្ញានេះ ដោយសម្រួលដល់ការអនុម័ត វិធានការច្បាប់ ឬវិធានការផ្សេងទៀត ដែលចាំបាច់ ដើម្បីធ្វើឲ្យសម្រេចបាននូវសិទ្ធិទាំងឡាយ ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ។<br>៣.រដ្ឋភាគីនៃកាតិកាសញ្ញានេះ សន្យាៈ<br>(ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាព របស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឲ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះបានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ។<br>(ខ) ធានាថា ជនណាដែលប្តឹងឲ្យមានការដោះស្រាយបែបនេះ ត្រូវមានសិទ្ធិឲ្យអាជ្ញាធរមានសមត្ថកិច្ចខាងយុត្តិធម៌ ខាងរដ្ឋបាល ឬខាងនីតិបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតសម្រេចឲ្យខ្លួន ដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផង។<br>(គ) ធានាថា អាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុវត្តឲ្យបាននូវដំណោះស្រាយដែលបានសម្រេចហើយ។ | ទ្ធិប្រជាពលរដ្ឋ និង នយោបាយ |
| | **ឋានានុក្រមនៃច្បាប់** | |
| **១៧** | មាត្រា ១៥០ថ្មី.- )<br>រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។<br>ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។ | ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ |
| **១៨** | ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស តែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់។ ពាក្យថាច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិរួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិងច្បាប់អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ។ | សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ ០៩២/០០៣/២០០៧/កបធ.ច ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ |

| | | |
|---|---|---|
| ១៩ | មាត្រា៦៧.-<br>បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិ ទាក់ទងនឹងច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ត្រូវយកមកអនុវត្តជាមួយនឹងច្បាប់នេះបាន ។<br>ក្នុងករណីមានទំនាស់ជាមួយនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។ | ច្បាប់ ស្តីពី សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ ២០០៣ |
| ២០ | មាត្រា៤៩.-<br>ដីកាឃុំសង្កាត់ មានប្រសិទ្ធភាពអនុវត្តនៅក្នុងវង្វង់ដែនដីរបស់ខ្លួនតែប៉ុណ្ណោះ ។<br>ដីកាឃុំសង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។<br>ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំសង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ត្រូវចាត់ទុកជាមោឃៈដាច់ខាត ។<br>រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំសង្កាត់សាមី និងត្រូវផ្សព្វផ្សាយជាសាធារណៈ ។ | ច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ឆ្នាំ ២០០១។ |
| ២១ | មាត្រា ២៤.-<br>បទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិទាំងឡាយណា ដែលទាក់ទងនឹងការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម និងដែលព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគី ត្រូវយកមកអនុវត្តជាមួយច្បាប់នេះ ។<br>ករណីមានទំនាស់ជាមួយនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិទាំងនោះ ត្រូវចាត់ទុកជាបទប្ប ញ្ញត្តិគោល ។ | ច្បាប់ ស្តីពី ការហាមឃាត់ អាវុធនុក្លេអ៊ែរ ឆ្នាំ ២០០៩ |
| ២២ | មាត្រា ១៦.-<br>ពន្ធ អាករ និងចំណូលសារពើពន្ធផ្សេងៗ ត្រូវកំណត់ដោយច្បាប់ និងត្រូវប្រមូល និងត្រួតពិនិត្យដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។អត្រាពន្ធអាករ មូលដ្ឋានជាប់ពន្ធ ការលើកលែងពន្ធ និងវិវាទ ដែលទាក់ទងនឹងការកំណត់ការប្រមូលនិងការត្រួតពិនិត្យពន្ធ ត្រូវកំណត់ក្នុងក្របខណ្ឌ និងតាមបែបបទ ដែលមានចែងនៅក្នុងច្បាប់ដែលទាក់ទងដល់ប្រភេទពន្ធ និងអាករនីមួយៗ ។<br>គ្មានបទប្បញ្ញត្តិណាមួយ ទោះជាប្រភេទណាក៏ដោយ គ្មានការអនុសញ្ញាអន្តរជាតិណាមួយដែលអាចធ្វើឱ្យមានការប្រែប្រួល នាំមកនូវការបាត់ចំណូលនោះឡើយ ។ ករណីខាងលើអាចប្រព្រឹត្តទៅបានលុះត្រាតែអនុវត្តតាមទម្រង់ច្បាប់ និង | ច្បាប់ ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨ |

| | | |
|---|---|---|
| | បទបញ្ជាដូចគ្នា ក្រោយពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។<br>ការប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ | |
| | **ផ្សេងៗ** | |
| ២៣ | មាត្រា៨.-<br>ត្រូវទប់ស្កាត់ផងដែរចំពោះអំពើគំរាមកំហែងក្នុងគោលបំណងឱ្យជនរងគ្រោះភ័យខ្លាច តក់ស្លុត និងអំពើប៉ះពាល់ដល់បុគ្គលភាព និងទ្រព្យសម្បត្តិនៃជនដែលរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារតែមួយ ។<br>មិនរាប់បញ្ចូលថាជាការប្រើហិង្សា ឬសកម្មភាពហិង្សាក្នុងគ្រួសារទេ រាល់ការប្រៀនប្រដៅដោយផ្តល់ដំបូន្មាន ឬធ្វើការដាស់តឿនក្រើនរំលឹកឬចាត់វិធានការនានាសមស្របដើម្បីឱ្យសហព័ទ្ធ ឬកូន ឬអ្នកនៅក្នុងបន្ទុកដើរក្នុងផ្លូវល្អតាមលក្ខណៈរស់នៅថ្លៃថ្នូរ និងទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ ប្រសិនបើការប្រៀនប្រដៅនិងការអប់រំនោះ ធ្វើឡើងប្រកបដោយព្រហ្មវិហារធម៌ និងស្របទៅតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា ។ | ច្បាប់ ស្តីពីការទប់ស្កាត់ អំពើហិង្សាក្នុងគ្រួសារឆ្នាំ ២០០៥ |
| ២៤ | មាត្រា ២៦៥ បទបដិសេធក្នុងការផ្តល់ទ្រព្យសម្បត្តិ ឬសេវា<br>អំពើដែលមិនព្រមផ្តល់ទ្រព្យសម្បត្តិ ឬសេវាដល់បុគ្គលណាម្នាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀលទៅ ២ ០០០ ០០០ (ពីរលាន) រៀល កាលបើការមិនព្រមនេះ ផ្អែកលើមូលហេតុណាមួយដូចតទៅ ៖<br>១-....។<br>៦- ភេទរបស់បុគ្គល ។<br>៨- .... | ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ |
| ២៥ | មាត្រា ២៦៧ បទបដិសេធក្នុងការជួលបុគ្គលឱ្យធ្វើការ<br>ការមិនព្រមជួលបុគ្គលណាម្នាក់ឱ្យធ្វើការត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀលទៅ ២ ០០០ ០០០ (ពីរលាន) រៀល កាលបើការមិនព្រមជួលនេះផ្អែកលើមូលហេតុណាមួយដូចមានចែងនៅចំណុចទី១ ដល់ចំណុចទី៨ នៃមាត្រា ២៦៥ (បទបដិសេធក្នុងការផ្តល់ទ្រព្យសម្បត្តិ ឬសេវា) នៃក្រមនេះ ។ | ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ |
| ២៦ | មាត្រា ១២..-<br>វៀរលែងតែមានបទប្បញ្ញត្តិនៃច្បាប់ការងារនេះបញ្ជាក់ច្បាស់ ឬអត្ថបទដទៃទៀតដែលមានលក្ខណៈជាច្បាប់ ឬជាបទបញ្ជាដែលការពារស្ត្រីនិងកូនក្មេង ក៏ | ច្បាប់ស្តីពី ការងារឆ្នាំ ១៩៩៧ |

| | | |
|---|---|---|
| | ដូចជាបទប្បញ្ញត្តិទាំងឡាយដែលទាក់ទងនឹងការចូលមកក្នុងប្រទេស និងការស្នាក់នៅនៃជនបរទេសបញ្ជាក់ច្បាស់ ថាគ្មាននិយោជកណាម្នាក់ អាចយកបញ្ហា ៖<br>... ភេទ....។<br>ការបែងចែក ការបដិសេធន៍ ឬការព្រមទទួល ដែលផ្អែកទៅលើលក្ខណៈសម្បត្តិជាកំណត់សម្រាប់មុខរបរណាមួយ មិនត្រូវចាត់ទុកជាការរើសអើងឡើយ ។ | |
| ២៧ | មាត្រា ៧៤៣.- លក្ខខណ្ឌ និងការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ<br>១- បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ។<br>២- បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើងដោយសារ មានករណីយកិច្ចធ្វើអំពើណាមួយតែមិនបានធ្វើអំពើនោះ។<br>៣- ចំពោះកំហុសចេតនា ឬកំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និងការកើតឡើងនៃការខូចខាត និងការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលសិទ្ធិទាមទារសំណងការខូចខាតនោះ ត្រូវបញ្ជាក់បង្ហាញលើកលែងតែបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬច្បាប់ផ្សេងទៀត។ | ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ |
| ២៨ | មាត្រា ៧៤៩.- អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ<br>១- បើមន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ដោយកំហុសចេតនា ឬដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ។<br>២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ បើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការ ក្នុងការជៀសវាងនូវលទ្ធផលមានភាពធ្ងន់ធ្ងរ រដ្ឋ ឬស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន។ | ដូចខាងលើ |
| ២៩ | យល់ឃើញថាជនជាប់ចោទ...ត្រូវបានឃុំខ្លួន...មានមូលហេតុស្របច្បាប់...តាមស្មារតី...មាត្រា៩ ចំណុចទី៣ វាក្យខណ្ឌ២ នៃអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ...តាមមាត្រា១២ ចំណុចទី២ នៃអនុសញ្ញាដដែល គឺកំណត់ផងដែរថា ជនជាប់ចោទត្រូវបានសន្មត់ថាជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់។...តុលាការកំពូលគប្បីពិចារណា<u>អំពីសិទ្ធិសេរី</u>ភាពរបស់ជនជាប់ឃុំ ។ | សាលដីកាតុលាការកំពូលលេខ ៣០៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ទំ.១២ |
| ៣០ | *...យោងដល់មាត្រា ១៤ (ឆ) នៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបា* | សាលដីកាតុលាការកំ |

| | | |
|---|---|---|
| | *យ ទទួលស្គាល់ក្នុងមាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញ...* | ពូលលេខ ២៣៩ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩។ |
| ៣១ | ពិចារណាថាព្រះរាជាណាចក្រកម្ពុជា ជាហត្ថលេខីនៃអនុសញ្ញា ស្តីពីការបង្ការ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍ ចុះហត្ថលេខាដោយ... | សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៩។ |